
PRIMERICA
A Citi Company
Chanthy Sek &
Shawn Dougherty
Bus: 1-866-582-3172
Cell: 267-984-8554
Life Insurance ធានារ៉ាប់រងជីវិត
Car Insurance ធានារ៉ាប់រងរថយន្ត
Refinance Your Debts រៀបចំសងប្រាក់ជំពាក់ឡើងវិញ
Investments វិនិយោគទុន
Office or Home Appointment. ជួបនៅការិយាល័យយើង ឬនៅផ្ទះលោកអ្នកក៏បាន
We also provide translation and interpretation services.
E-mail: 8665823172@primerica.gosolo.com
Primerica Financial Services. 1035 Virginia Dr., Ste 100H. Ft. Washington, Pa 19034



# ខ្មែរប៉ុស្តិ៍
# The Khmer Post
ISSUE 35 28th April-12th June 2009



ហាងមាសស្រី
SUNSHINE JEWELRY INC
•Fine Jewelry
•Certified Diamonds & Custom Design
មានលក់គ្រឿង អលង្ការ យ៉ាងប្រណិតបំផុត មេញសញ្ញាបត្រឈើពេជ្រអាច ផ្លាក់ ឬ ថ្លៃ មាស ប្រាក់ ពេជ្រ ជូនបានតាមបំណង ។
702 Washington Avenue
Philadelphia, Pa 19147
Phone: (215) 271-2950
Fax: (215) 271-2962
Email: colorofsunshine@yahoo.com


## បទសម្ភាសន៍អ្នកឃើញគេយកស៊ីន ស៊ីសាមុត ទៅសម្លាប់

កណ្តាល, ខ្មែរប៉ុស្តិ៍ : ប៊ុត ប្ញ


លោក ស៊ីន ស៊ីសាមុត

●●● ជាង៣០ឆ្នាំមកហើយ ដែលសារព័ត៌មានមួយចំនួនបានអះអាងអំពីជីវប្រវត្តិសិល្បករចាស់ៗមិនច្បាស់លាស់នោះ ។ ពេលនេះសារព័ត៌មានខ្មែរប៉ុស្តិ៍ (តទៅទំព័រទី ១២)

## កម្ពុជា_សៀមសម្លេងទ័ព និងអាវុធដាក់គ្នា

ខ្មែរប៉ុស្តិ៍ : ស៊ុម សុភាឫទ្ធិ



●●● ចាប់តាំងពីប្រាសាទព្រះវិហារត្រូវបានអង្គការយូណេស្កូចាត់បញ្ចូលជាសម្បត្តិ (តទៅទំព័រទី ០៥)

វិចារណកថា

## សេចក្តីសង្ឃឹមផ្តើមនៅវត្តព្រះពុទ្ធរង្សី

ដោយ : ពិន សំខុន

●●● ភាពរាំរែកសំដែងការអបអរសាទរនាឆ្នាំថ្មី រៀបចំជូនពរពលរដ្ឋខ្មែរ នៅវត្តព្រះពុទ្ធរង្សី ឆ្នាំនេះ ធ្វើឱ្យគេនឹកឃើញដល់សន្តិភាពនៃកម្ពុជា នាអំឡុងឆ្នាំ ១៩៦០ ដែលគេអាចលើកគ្នាទៅធ្វើបុណ្យនៅស្រុកកំណើត ឬប្រមូលគ្នាទៅលេងភ្លេងរាំកំសាន្ត នៅអន្លង់រមាត ពីភូមិទៅភូមិមួយ បានដោយគ្មានការព្រួយបារម្ភ ។ បន្ថែមពីលើកុសលដែលបានពីភាពរីករាយក្នុងឱកាសដ៏ពិសេសក្នុង១ឆ្នាំមានម្តងនោះ គេបានសង្កេតឃើញសេចក្តីសង្ឃឹមថ្មីមួយ (តទៅទំព័រទី ០៩)





Mobile-net
We connect you to the world!
Since 1995
6.9¢
កម្ពុជា
ចុះឈ្មោះថ្ងៃនេះ នឹងទទួលបាន 133 នាទី សំរាប់ទូរស័ព្ទទៅកម្ពុជា ដោយឥតយកកំរៃ !
1.9¢
ថៃឡង់
5.5¢
ឡាវ
សេវាទូរស័ព្ទអន្តរជាតិដ៏ប្រសើរបំផុត
រកភ្នាក់ងារធ្វើការ
គ្មានកាលកំណត់
គ្មានយកកំរៃលើការតភ្ជាប់ប្រព័ន្ធ
គ្មានយកកំរៃលើការថែទាំ
គ្មានតម្លៃប្រែប្រួល
my011.com
1(800) 818-9000


## លោក ហោ ណាំហុង សន្លប់នៅពេលសម្ពោធកុងស៊ុលថ្មី

ខ្មែរប៉ុស្តិ៍.


លោក ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រីខ្មែរ

Lowell : លោកឧបនាយករដ្ឋមន្ត្រីខ្មែរ ហោ ណាំហុង បានសន្លប់បាត់ស្មារតី នៅពេលដែលលោកកំពុងថ្លែងសន្ទរកថាចំពោះមុខភ្ញៀវកិត្តិយសដែលមកចូលរួមក្នុងកម្មពិធីសម្ពោធអគ្គកុងស៊ុលខ្មែរដំបូងបង្អស់ នៅទីក្រុង ឡូវែល រដ្ឋ ម៉ាសាឈូសេត ។

(តទៅទំព័រទី ២០)


ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ_អង្គរ
Angkor International Travel Agency
World Wide Travel & Tour Services
Cambodia – Vietnam – Laos – Thailand
(Since 1991)
USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
Cambodia: Victory Travel
No. 96 Eo Street. 148, Phsar Kandal
Phnom Penh, Cambodia
Tel: 011-892329
Manager SIN PO
CHENDA: 023-221069
Serving all Major air lines :
. SINGAPOR
. EVA AIR
. KOREAN AIRLINES
. MALAYSIA etc...

# មានអ្វីប្លែកនៅខ្មែរខាងកើត

១-សិស្សខ្មែរចំនួន ៨នាក់ បានរៀបចំបង្ហាញសំលៀកបំពាក់ប្រពៃណីនៅមជ្ឈមណ្ឌល E3 Center នាឱកាសចូលឆ្នាំថ្មី ថ្ងៃទី១៥ មេសា កន្លងទៅនេះ ។ នេះជាឆ្នាំទីពីរ ដែលកូនសិស្សខ្មែរកើតឡើងបាន ដោយបានបង្ហាញរបាំខ្មែរ សំពត់អាវខ្មែរ ភ្លេងខ្មែរ មានទទួលអាហារ និងភេសជ្ជៈផង ។ សកម្មភាពមានការចូលរួមដោយសិស្សអាមេរិកាំង៤នាក់ទៀតផង ។



ក្មេងប្រមាណ ៤០នាក់ បានចូលរួមអបអរចូលឆ្នាំថ្មី ជាមួយសិស្សខ្មែរ ដែលនាយកសាលាអ្នកស្រី ម៉ារីយ៉ា ធុយ និយាយថា" ជាសកម្មភាព ដែលនឹងធ្វើឱ្យសិស្សរឹតតែចូលចិត្តសាលារៀនច្រើនឡើង " ។ ដែលជាងអតីត " អ្នកបោះបង់សាលា " បានរៀបចំបង្ហាញវប្បធម៌ខ្មែរ ដល់សិស្សឯទៀតៗ និងមាតាបិតាដែលនៅក្នុងតំបន់ ។





ឆាណា, សុគន្ធា, ម៉ារ៉ាឌី, ជេនីកា, គីម, លួន, ឃុន, និង សាំង បានខិតខំធ្វើឱ្យពិធីចូលឆ្នាំនេះ

## ២- ហីប ហុប ក្នុងភាសាខ្មែរអាមេរិកាំង :

"តូនី ទូន " គឺជាក្រុមសម្តែងរបាំសម័យរបស់យុវជនខ្មែរមួយក្រុមមកពីកម្ពុជា ដើម្បីបង្ហាញ Break Danse Hip Hop នៅសហរដ្ឋអាមេរិកនេះ ។ ក្រុមនេះបានមកសម្តែងរបាំសម័យថ្មី ស្រឡាងនៅមណ្ឌលដ៏ចំណាស់មួយមានអាយុកាលរាប់ពាន់ឆ្នាំ ដោយរូបគំនូរនិងចម្លាក់ខ្មែរនៅហ្វីឡាដែល-ហ្វីយ៉ា មណ្ឌលនោះ ឈ្មោះថា Khmer Art Gallery ។

(តនៅទំព័រទី ១០)


# ការិយាល័យច្បាប់របស់ ជេហ្វ្រី អិន ខែល



Law Offices of
**Jeffrey N. Kale**
Attorney at Law



ពិគ្រោះករណីច្បាប់ដោយមិនគិតកំរៃ យើងបានបំរើសេវាច្បាប់ជូនដល់សហគមន៍ខ្មែរជាង២០ឆ្នាំហើយ .ការិយាល័យ "ច្បាប់ទូទៅ" ដែលមានជំនាញផ្នែកច្បាប់ដូចតទៅ:

- គ្រោះថ្នាក់រថយន្ត
- បើកបរក្រោមឥទ្ធិពលស្រវឹង ឬពុល
- មានរបួសនៅកន្លែងធ្វើការ
- ទិញលក់អចលនវត្ថុ
- ច្បាប់បើកក្រុមហ៊ុន
- ច្បាប់ឧក្រិដ្ឋកម្ម
- គ្រោះថ្នាក់ដោយរអិល ឬដួល
- រំលោភច្បាប់លើផ្លូវចរាចរ
- ការទារឱ្យសងប្រាក់ជំពាក់ ។ល។

**New Jersey : 856-216-7171**
**1236 Brace Road, Suite K, Cherry Hill, NJ 08034**
**Pennsylvania/Philadelphia: 215-564-6900**
**1700 Sansom St., 3rd Floor, Street, Philadelphia, PA 19103**

**FREE CONSULTATIONS**
Providing legal services to the Cambodian community for 20 years
General Law Office specializing in the following areas of law:

| | |
|---|---|
| Car Accidents | Criminal Law |
| DUI/DWI | Slip & Fall Accidents |
| Workplace Injury | Traffic Violations |
| Real Estate | Collections |
| Corporate Law | |

សេវាច្បាប់ប្រកបដោយវិជ្ជាជីវៈ និងតម្លៃគួរសមអាចមានអ្នកបកប្រែជូនបាន





# ADAMS DENTAL CENTER

801 ADAMS AVENUE. PHILADELPHIA, PA 19124. TEL: 215-744-8300





សូមអញ្ជើញមកមជ្ឈមណ្ឌលធ្មេញ "អាដាប" យើងធ្វើចុនពីដើមដល់ចប់បានយើងមានក្រុមទន្តបណ្ឌិត៥រូប ដែលមានជំនាញគ្រប់គ្រាន់ជ្រោយនៃវិជ្ជាធ្វើធ្មេញ ។

មណ្ឌលធ្មេញឯកទេស ខាងការទារណ៍អរ

**ឯកទេសខាង**

- ✓ Crowns,
- ✓ Braces,
- ✓ Bridges,
- ✓ Veneers,
- ✓ Inlay,
- ✓ Gold Caps,
- ✓ Implants,
- ✓ Full & Partial Dentures.

យើងជាមជ្ឈមណ្ឌលនៅហ្វីឡាដែលហៀតែមួយដែលមានបន្ទប់ពិសោធន៍ នៅជាមួយគ្នានេះទីនោះ លោក-អ្នកអាចប្តូរធ្មេញជំនួសដែលផលិតឡើងតាមគុណភាពដែលលោកអ្នកចង់បានទាំងអស់ សុទ្ធតែដំណើរការដោយបច្ចេកទេសវិជ្ជាជាន់ខ្ពស់ ហើយប្រើលំនាំប្រព័ន្ធ OSHA ជាក្បួន។

**ទន្តសាស្ត្រទូទៅ**

- -ដកធ្មេញ
- -បំពេញធ្មេញប្រហោង
- -ព្យាបាលប្រហោងដល់ឫសធ្មេញ
- -ផ្ចិតចន្លោះធ្មេញមុខ-ធ្មេញបាក់ ធ្មេញស្រោម ឬធ្មេញដង្កូវស៊ី
- -សំអាតធ្មេញឱ្យស្អាត: ដោយធ្វើដោយឡេស័រមួយម៉ោង ឬយកប្រដាប់ទៅសំអាតនៅផ្ទះ
- -យើងក៏មានធ្វើការសំអាតដោយ "អុលត្រាសោន" ដែលធ្វើមិនឱ្យយើងឈឺ

**បើកមជ្ឈមណ្ឌល**

| | |
|---|---|
| ថ្ងៃ ចន្ទ | : 10am-6pm |
| ថ្ងៃ អង្គារ | : 10am-6pm |
| ថ្ងៃ ពុធ | : 10am-7pm. |
| ថ្ងៃ ព្រហស្បតិ៍ | : 10am-6pm |
| ថ្ងៃ សុក្រ | : 10am-6pm. |
| ថ្ងៃ សៅរ៍ | : 10am-7pm |

**យើងទទួលយកផែនការណ៍ជួយធ្វើធ្មេញស្ទើរតែទាំងអស់**

Cigna Dental, 1201 Dental Plan, Delta Dental, DHA, Guardian,Aetna,PPO, Ameri-Health, United Concordia Flex, MetLife, Unicare.

**បញ្ចុះថ្លៃ 10% ដល់អ្នកគ្មានប័ណ្ណសុខភាព**

អាចធ្វើផែនការណ៍បង់ថ្លៃរាល់ខែ

# សិទ្ធា សាន ក្លាយខ្លួនជាស្ត្រីឆ្នើមម្នាក់



**ឡុងប៊ិច, ខ្មែរប៉ុស្តិ៍ : វ៉ា នាថ**

•••ក្នុងសំដីដែលបានថ្លែងចេញនៅចំពោះមុនភ្ញៀវអន្តរជាតិរាប់រយនាក់ ដែលលាយឡំជាមួយដំណក់ទឹកភ្នែកហូរស្រក់ ព្រោះតែក្តីរំភើបដែលខ្លួនធ្លាប់ជាអតីតជនរងគ្រោះម្នាក់ក្នុងរបបវាលពិឃាតកាប់សម្លាប់រង្គាល ត្រូវអង្គការពិភពលោកមួយ បានវាយតម្លៃ និងលើកតម្កើងខ្លួនឱ្យក្លាយជាស្ត្រីឆ្នើមម្នាក់ (វិរៈនារី) ដែលមានប្រយោជន៍ចំពោះសង្គមជាតិ ។

ស្ត្រីឆ្នើមចម្រុះជាតិសាសន៍ចំនួន 9នាក់ ត្រូវបានទទួល ការលើកសរសើរជាវិរៈនារីរបស់ទីក្រុង Long Beach នាក់ ក្នុងកម្មវិធីស្ត្រីដ៏អស្ចារ្យនៃស្នាដៃខុសៗគ្នា នាឆ្នាំ 2009 ពីអង្គការ Soroptimist International ។

ស្ត្រីដែលមានស្នាដៃក្នុងសង្គមខុសៗគ្នា ពីសមត្ថភាពជំនាញការងារ ដែលបានលើកតម្លៃឱ្យជាស្ត្រីឆ្នើម ដូចជាកិច្ចការសកម្មទៅលើផ្នែកសុខមាលភាព ។

ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ការអប់រំផ្នែកសិទ្ធិស្ត្រី និងកុមារ និងចំណេះដឹងទូទៅ កិច្ចការផ្នែកទំនាក់ទំនងល្អ និងយល់ដឹងលក្ខណៈអន្តរ-ជាតិជាដើម ។

សិទ្ធា សាន ក្នុងអការៈដៃជូតទឹកភ្នែក ថ្លែងទៅកាន់ភ្ញៀវកិត្តិយស ដែលចូលរួមកាលពីដើមខែមេសានេះ អ្នកស្រីបានបង្ហាញនូវបេះដូងពីមោទនភាពរបស់ខ្លួនថា អ្នកស្រីជាអតីតអ្នកទោសខ្មែរក្រហម នាអំឡុងឆ្នាំ 1975-1978 ក្នុងវ័យជាង 10 ឆ្នាំ ដែលរស់នៅដោយភាពអត់ឃ្លានដាច់បាយក្រហាយទឹក ជួបនូវទារុណកម្ម ពីការធ្វើបាបក្នុងរបប ប៉ុល ពត ក្រោមពាក្យស្លោករបស់ពួកអាវខ្មៅនិយាយថា " ទុកក៏មិនចំណេញ ដកចេញក៏មិនខាត " ដែលបងប្អូនរបស់អ្នកស្រីត្រូវគេសម្លាប់ និងបង្ខំឱ្យធ្វើការហួសកម្លាំង ដូចជាអ្នកទោស បានក្លាយខ្លួនជាស្ត្រីម្នាក់ ដែលត្រូវបានលើកស្ទួយឱ្យក្លាយជាស្ត្រីឆ្នើមរបស់អង្គការពិភពលោកមួយ គឺកិត្តិយសរបស់កូនខ្មែរជាតិខ្មែរ ដែលចេញពីការប្តេជ្ញាចិត្ត និងស្មារតីលះបង់រួមនឹងការសហការគ្នាជាមួយប្រជាជន ជាមួយសមាគមន៍ ដែលបាននាំជីវិតរបស់យើងឈានទៅរកភាពជោគជ័យ ។

សិទ្ធា សាន បានបង្ហាញពីជោគសំណាងរបស់អ្នកស្រីថា ប្រទេសកំណើតទី2 របស់អ្នកស្រីបានផ្តល់ឱ្យ នាងនូវជោគជ័យពីឆាកជីវិតមានចំណេះដឹងខ្ពង់ខ្ពស់ថ្នាក់បរិញ្ញាប័ត្រពីការមិនមានសម្លៀកបំពាក់ និងការហូបមិនគ្រប់គ្រាន់បានក្លាយទៅជាមនុស្សម្នាក់ក្នុងសម្លៀកបំពាក់សមរម្យ មានអាហារនៅលើតុ ដែលចំណងនេះ បាននាំឱ្យយើងមានកម្លាំង សមត្ថភាពជួយការងារ និងអភិវឌ្ឍន៍សហគមន៍ខ្មែរ នៅ Long Beach ។

សិទ្ធា សាន បានអះអាងថា ប្រសិនបើអ្នកចង់ជោគជ័យក្នុងជីវិត យើងត្រូវយល់ដឹង និងស្គាល់អ្វីដែលអ្នកចង់ឱ្យរីកចំរើន, ស្គាល់អ្វីដែលអ្នកត្រូវធ្វើជាមួយអ្នកណាដែលជាធ្វើជាដៃគូដើម្បីភាពរីកចំរើន សំរាប់គោលបំណងរបស់អ្នក, កសាងទំនាក់ទំនងអ្វីមួយដែលអាចជួយអ្នកឱ្យឈានទៅមុនក្នុងគោលបំណងជោគជ័យក្នុងជីវិតរបស់អ្នក, ធ្វើការដោយហ្មត់ចត់ ដោយស្គាល់ខ្លួនឯងថា ត្រូវតែបង្កើននូវភាពជោគជ័យរបស់អ្នក និងការទទួលផលមកវិញ ដែលអ្នកបានបង្កើននូវភាពជោគជ័យរបស់អ្នកបន្តការជួយទៅអ្នកដទៃឱ្យជោគជ័យក្នុងការងារដ៏ហ្មត់ចត់ ដែលវាគឺជាដោយស្គាល់ខ្លួនឯងថា ត្រូវតែបង្កើននូវភាពជោគជ័យរបស់អ្នក និងការទទួលផលមកវិញ ដែលអ្នកបានបង្កើននូវភាពជោគជ័យរបស់អ្នក

(តទៅទំព័រទី ២០)




អ្នកស្រី សិទ្ធា សាន ក្នុងថ្ងៃទទួលកិត្តិយសជាស្ត្រីឆ្នើមរបស់អង្គការពិភពលោកមួយ (រូបខ្មែរប៉ុស្តិ៍ : ម៉ាន់ថា ឯល)


# BALDI FUNERAL HOME

1331 S. Broad St. Philadelphia, Pa 19147

Cell: 267-934-9888 / Tel : 215-389-2414

**សូមសួររកលោក សេង ឬ Thomas**

### ឈាបណកិច្ចតាមប្រពៃណី

ឈាបណដ្ឋានមានផ្តល់ជូននូវក្តារមឈូស ទីធ្លាសំរាប់បញ្ចុះ រៀបកំរងផ្កា និងសេវាឈាបណកិច្ចច្រើនប្រភេទ តម្លៃទៅតាមប្រភេទដែលត្រូវការសេវាឈាបណកិច្ចតាមវប្បធម៌ និងតាមសាសនា និងបំពេញជូនជាកិត្តិយស យើងនឹងខំឱ្យអស់ពីសមត្ថភាព ដើម្បីបំពេញសេចក្តីត្រូវការ និងបំពេញប្រាថ្នារបស់លោកអ្នក ។

### ពិធីបូជាសព

"បាល់ឌី" ផ្តល់ជូននូវពិធីបូជាសពគ្រប់បែបជម្រើសរាប់ទាំងឱ្យភ្លើង ក្តារមឈូសសំរាប់សពទន្ទឹមនោះមានសេវាពិធីបុណ្យតាមវប្បធម៌ ការតម្កល់អដ្ឋិ-ធាតុជាចុងបញ្ចប់។ មានជួយធ្វើលិខិតក្នុងករណីចង់នាំអដ្ឋិធាតុទៅកាន់ប្រទេសមួយទៀត មានចារឈ្មោះសពនៅលើទំព័រ "ខ្មែរប៉ុស្តិ៍" ជូនផង ។




**(Locates in South Philly, convenience traffic, and free parking)**

### Traditional Funeral

Funeral Home provides caskets, cemetery space, floral arrangements, and funeral service options in various price ranges. Cultural and Religious funeral service is honored. We put full efforts to meet your needs and fulfill your wishes.

### Cremation

Baldi offers complete cremation options including a combustible casket for the body, on site performing cultural memorial service, final placement of the cremated remains, paperwork assistance in case that need to transport the cremated remains to another country, and the Khmer Post newspaper notices.

# គណបក្ស សម រង្ស៊ី : "រដ្ឋាភិបាលកំពុងអនុវត្តន៍នយោបាយខ្មែរក្រហម"

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ឃុត សីហា**

●●●ក្នុងពិធីរម្លឹកខួបដល់ជនរងគ្រោះនៅឯវាលពិឃាតបឹងជើងឯក ដែលជាកន្លែងធ្វើទារុណកម្ម និងកាប់សម្លាប់មនុស្សអស់ជិត១ម៉ឺននាក់ ក្រោមការត្រួតត្រារបស់កាំង ហ្គេចអ៊ាវ ហៅ ឌុច នោះ ថ្នាក់ ដឹកនាំគណបក្ស សម រង្ស៊ី បានថ្លែងទៅកាន់ព្រះសង្ឃ និងក្រុមគ្រួសារជនរងគ្រោះថា "សមាសភាពរបស់ពួកខ្មែរក្រហមបានបន្តអំពើឃោរឃៅរបស់ខ្លួន មិនឈប់ឈររហូតដល់បច្ចុប្បន្ន" ។

លោក គង់ គាំ អនុប្រធានគណបក្ស សម រង្ស៊ី បានថ្លែងថា ការជម្លៀសប្រជាជនកម្ពុជាចេញពីទីក្រុងរបស់ពួកខ្មែរក្រហម បើប្រៀបធៀបនឹងការជម្លៀសនេះទៅនឹងការបណ្តេញចេញទាំងបង្ខំមួយចំនួន ដែលបានកើតឡើងក្នុងជម្លោះដីធ្លីបច្ចុប្បន្នវាដូចគ្នាខ្លាំងណាស់ ។

អនុប្រធានគណបក្ស សម រង្ស៊ី បាន បន្តថា ការអនុវត្តដូចគ្នា នេះបានស្ថិតនៅក្រោមឥទ្ធិពលរបស់សមាសភាពខ្មែរក្រហមនោះ នៅតែសម្លាប់ និងបណ្តេញប្រជាជនចេញពីផ្ទះសម្បែង ដីធ្លីរបស់ខ្លួន ស្ទើរគ្រប់ទីកន្លែង ។ ទង្វើបែបនេះបានបង្កឱ្យមនុស្សជាច្រើនខ្វះទីជម្រក ដីធ្លី ខ្វះចំណីអាហារ ប៉ះពាល់ដល់សុខភាពយ៉ាងខ្លាំង ។ អ្នកខ្លះទៀតហាក់ដូចជាមិនទាន់បានគេចផុតពីរបប ប៉ុល ពត ដ៏ខ្មៅងងឹតនៅឡើយទេសព្វថ្ងៃនេះ ។



លោក គង់ គាំ ប្រធានគណបក្ស សម រង្ស៊ី



សារមន្ទីរប្រល័យពូជសាសន៍បឹងជើងឯក

លោក ជាម យៀប សមាជិកសភាគណបក្សប្រជាជនកម្ពុជា ដែលត្រូវបានកាសែតក្នុងស្រុកដកស្រង់សម្តីថា "នេះជាការរៀបចំ ប្រជាភិថុតដើម្បីទាក់ទាញការចាប់អារម្មណ៍ប៉ុណ្ណោះ" ។ យើងចាត់ទុកថ្ងៃ17 មេសា ជាថ្ងៃដែលប្រទេសជាតិ និងប្រជាជនធ្លាក់ក្នុងគ្រោះមហន្តរាយ និងការចាប់ផ្តើមនៃរបប ប៉ុល ពត គឺវាមិនត្រូវចាត់ទុកជាថ្ងៃបុណ្យជាតិនោះទេ ។

លោក ជាម យៀប បន្តថា លោក គង់ គាំ មិនទទួលស្គាល់ការផ្លាស់ប្តូររបស់ប្រទេសជាតិបន្ទាប់ ពីពួកខ្មែរក្រហមដួលរលំនៅឆ្នាំ 1979 ហើយ បើគ្មានថ្ងៃ 7 មករា 1979 ក្រុមរបស់លោក សម រង្ស៊ី ក៏មិនបានចូលក្នុងស្រុកដែរ ។

គណបក្សប្រជាជនកម្ពុជាដែលបានបង្កើតរណសិរ្សរំដោះជាតិ បានបង្កើតឡើងនៅឆ្នាំ 1978 ប្រឆាំងនឹងពួកខ្មែរក្រហម ក្រោមការដឹកនាំរបស់លោក ប៉ែន សុវណ្ណ ហេង សំរិន, ជា ស៊ីម, និង ហ៊ុន សែន ដែលមានការគាំទ្រពីសំណាក់កងទ័ពយួន ។ ដោយសារតែថ្ងៃ 7 មករា 1979 នេះហើយពួកយួនក៏បានចូលលុកលុយប្រទេសកម្ពុជា និងបញ្ជូនជាតិសាសន៍គេឱ្យមករស់នៅស្រុកខ្មែរខុសច្បាប់កាន់តែច្រើនគ្រប់ទិសទី ព្រមទាំងមានឥទ្ធិពលក្នុងប្រទេសកម្ពុជាថែមទៀត ។

ក្នុងព្រឹត្តិការណ៍រម្លឹកឈឺចាប់នេះ លោក សម រង្ស៊ី កាលពីឆ្នាំ 2008 បានចោទប្រកាន់លោក ហោ ណាំហុង ថា ជាប់ពាក់ព័ន្ធនឹងមេគុកបឹងត្របែកនោះ ត្រូវបានលោក ហោ ណាំហុង ប្តឹងពីបទបរិហារកេរ្តិ៍ ហើយត្រូវតុលាការប្រទេសបារាំងកាត់ឱ្យចាញ់ក្តីរួចទៅហើយ ។

ក្នុងពិធីរម្លឹកការឈឺចាប់នៃព្រឹត្តិការណ៍ថ្ងៃ 17 មេសានោះ អ្នកស្រី ចាន់ គីមសួង អាយុ 63ឆ្នាំ ដែលបានឡើងមានចំណាប់អារម្មណ៍ បានសម្តែងនូវការឈឺចាប់យ៉ាងខ្លាំង ហើយអំពាវនាវឱ្យសាលាក្តីខ្មែរក្រហមកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមឱ្យបានឆាប់បំផុត ពីព្រោះក្នុងរបបនោះអ្នកស្រីបានបាត់បង់កូន និងប្តីអស់ពីខ្លួន រស់ស្ទើរគ្មានព្រលឹងក្នុងខ្លួនទេ ។ ជាពិសេសជន

(តទៅទំព័រទី ១៧)

NEW GOLDEN PALACE RESTAURANT
801-21 Washington Ave.
Phone: 215-627-2822

Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm

**Authentic Chinese & Vietnamese Cuisine**
**Very Delicious and Nutritious**

-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ

**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)

**ពិសេសដោយម្ចាស់ហាង:** មានចុះតម្លៃ **10%**លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement



Manager Special :
-10% OFF
LUNCH & DINNER
Present This Coupon

ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.

**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ត្រាំង ឆាសាច់គោ
- មីកន្ត្រាំងឆាគ្រឿងសមុទ្រ
- បាយឆាគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង



**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**
- នំបញ្ចុកទឹកត្រីពិសេស
- នំបុ័ងបាតេ ឬសាច់គោអាំង
- ខគោ នំបុ័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

តមកពីទំព័រទី ០១

# កម្ពុជា_សៀមសម្តែងទឹក...

បេតិកភណ្ឌពិភពលោករួចមក ពួកសៀមបានប្រើប្រាស់ យុទ្ធសាស្ត្រផ្សេងៗដើម្បីឈ្លានពានប្រទេសកម្ពុជា នៅចំណុចប្រាសាទព្រះវិហារ និងតាមបណ្តាខេត្តជាប់ព្រំប្រទល់នៃប្រទេសទាំងពីរយ៉ាងគឃ្លើន គឺគ្មានការកោតញញើតបន្តិចសោះឡើយ ។

រាយការណ៍ថា ទាហានរបស់ខ្លួនស្លាប់2នាក់ និងរបួស3នាក់ ក្រសួងការបរទេសសៀមថាទាហានខ្លួនស្លាប់2 និងរបួស6នាក់ ប៉ុន្តែប្រភពមន្ត្រីយោធាសៀមថា ស្លាប់10នាក់ និងរបួសម្នាក់ ។

លោក ស្រី ឌឹក មេបញ្ជាការកងយោធពល-ខេមរភូមិន្ទប្រចាំតំបន់ប្រាសាទព្រះវិហារ បាន

ក្នុងឆាកប្រយុទ្ធស៊ីសាច់ ហុតឈាមគ្នានោះទេ ។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី បានប្រាប់ក្រុមអ្នកយកព័ត៌មានថា នៅតំបន់សមរភូមិស្ថានការណ៍នៅតឹងតែងដដែល ហើយទាហានកម្ពុជាមានស្មារតីប្រុងប្រយ័ត្នគ្រប់ពេលវេលា ហើយភាគីសៀមបានចល័តទ័ពនៅតាមព្រំដែនឥតឈប់ឈរ ។

ការផ្ទុះអាវុធនៅសមរភូមិទាំង4លើកចុង

លោក មឿង សុន ប្រធានទ្រទ្រង់អរិយធម៌ខ្មែរបានចេញសេចក្តីថ្លែងការណ៍ថ្កោលទោសចំពោះការរំលោភឈ្លានពានរបស់ទាហានសៀមមកលើបូរណភាពទឹកដីខ្មែរ ដែលទង្វើនេះខុសធ្ងន់ធ្ងរណាស់ ។ ជាពិសេសធ្វើឱ្យខូចខាតប្រាង្គប្រាសាទបុរាណ ឆេះផ្ទះសម្បែងអ្នកស្រុក រត់ចោលភូមិឋានគួរឱ្យខ្លោចផ្សារយ៉ាងខ្លាំង ហើយលោកបានអំពាវនាវឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរដោះស្រាយដោយសន្តិវិធី ។

ប្រភពខាងលើបន្តថា ប្រសិនបើប្រមុខរដ្ឋា-ភិបាលខ្មែរ នៅតែចង់ធ្វើការចរចាទ្វេភាគីនោះវាគ្មានលទ្ធផលបន្តិចសោះ ពីព្រោះសៀម គេមានសេដ្ឋកិច្ចខ្ពស់ ប្រជាជនច្រើនមានអាវុធយុទ្ធភណ្ឌទំនើប ហើយអាចបង្កការប្រយុទ្ធគ្នារវាងទាហាននៃប្រទេសទាំងពីរប្រយុទ្ធគ្នានៅថ្ងៃមុខទៀត ។ ចំណែកប្រជាពលរដ្ឋដែលរស់នៅតាមព្រំដែនរងទុក្ខវេទនាគ្រប់ពេលវេលា ។





ប្រជាពលរដ្ឋខ្មែរកំពុងតែរត់គៀសខ្លួន ខណៈពេលដែលទាហានសៀមផ្លោងឆេះផ្សារ

ការបង្ហូរឈាមគ្នានៅតាមព្រំដែនកម្ពុជា-សៀមកាលពីដើមខែមេសាកន្លងមកនេះ ត្រូវបាននាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ថ្លែងថា ការផ្ទុះអាវុធនេះបានប្រើប្រាស់កាំភ្លើងយន្ត កាំភ្លើងត្បាល់ គ្រាប់រ៉ុកែត និងការវាយលុកដោយថ្មើរជើងនោះ បានបង្កឱ្យទាហានសៀម 20នាក់ស្លាប់ 30នាក់របួសធ្ងន់ និងចាប់ខ្លួនបានជាច្រើននាក់ វាជារឿងធម្មតា ។

ប្រភពពីមន្ត្រីការពារព្រំដែននៅជួរមុខ ចំណុចវាលឥន្ទ្រីយ៍បានប្រាប់ខ្មែរប៉ុស្តិ៍ថា ការផ្ទុះអាវុធយ៉ាងសាហាវនេះវាផ្តើមចេញពីពួកទាហានសៀមដែលព្យាយាមចូលមកលុកលុយទឹកដីកម្ពុជាតាមទំនើងចិត្ត មិនគោរពកិច្ចព្រមព្រៀង ហើយរុះរើជំរំរបស់ទាហានកម្ពុជាធ្វើឱ្យភាគីកម្ពុជាអត់ធ្មត់លែងបាន ក៏ប្រើប្រាស់សិទ្ធិការពារខ្លួន ។

ក្នុងការបង្ហូរឈាមកាលពីពេលកន្លងមកនេះ ទាហានកម្ពុជាបានគ្រប់គ្រងសមរភូមិ ត្រៀម4កន្លែង ហើយមេបញ្ជាការសៀមលើកទង់ជ័យសសុំចុះចាញ់ធ្វើការចរចា ដើម្បីសែងទាហានរបស់ខ្លួនទៅព្យាបាលរបួស និងបញ្ជូនសពឱ្យសាច់ញាតិឱ្យក្រុមគ្រួសារធ្វើបុណ្យតាមទំនៀមទម្លាប់ប្រពៃណី ។

ទោះបីជាយ៉ាងណា ស្ថានទូតសៀមបាន

ឱ្យដឹងថា កងទ័ពរបស់លោកមានការនឿយហត់ខ្លាំងណាស់ក្នុងការការពារទឹកដី បើទោះបីជាយ៉ាងនេះក្តី ក៏ពួកគេនៅតែប្រុងប្រៀបជានិច្ច ដើម្បីការពារទឹកដីមិនឱ្យខ្មាំងសត្រូវឈ្លានពានដែរ ។

យោងតាមកាសែតសៀម The Nation បានស្រង់សម្តីរបស់ឧត្តមសេនីយ៍ Wiboon Sak Neepan មេបញ្ជាការទាហានសៀមនៅភូមិភាគ2 បានឱ្យដឹងថា បញ្ជាការដ្ឋានទាហានជើងគោកសៀមបានអនុម័តកម្លាំងទ័ពបន្ថែមទៀតដើម្បីជួយទប់ទល់នៅតំបន់ប្រាសាទព្រះវិហារ ។ ការបញ្ជូនទ័ពនេះ គឺដើម្បីប្តូរវេនគ្នាអ្នកឈរជើងនៅសមរភូមិមុខឱ្យមកក្រោយវិញ ។

ចំណែកលោក កាណុត នេត្រាកាវេសនៈ បញ្ជាការកងទ័ពសៀមដែលបានជួបជាមួយនឹងលោក ស្រី ឌឹក នេះបានប្រាប់កាសែត The Nation ថា ប្រទេសទាំងពីរគ្មានផែនការដកទាហានរបស់ខ្លួនចេញពីតំបន់ជម្លោះនៅចំណុចប្រាសាទព្រះវិហារទេ ហើយការវាយប្រឈមមុខដាក់គ្នានៅថ្ងៃអនាគតវាអាចកើតមាន ពិបាកនឹងស្មានខ្លាំងណាស់ ។ ក្នុងការប្រយុទ្ធកន្លងមកមានទាហានសៀម22នាក់ស្លាប់ និង 30នាក់រងរបួស ចំណែកភាគីខ្មែរស្លាប់ពីរនាក់ ។ ប៉ុន្តែមន្ត្រីយោធាខ្មែរពុំបានបញ្ជាក់ថា ទាហានរបស់ខ្លួនស្លាប់

ក្រោយនេះ ទាហានសៀមបានធ្វើការបាញ់ផ្លោងសំដៅបំផ្លិចបំផ្លាញសម្បត្តិបេតិកភណ្ឌពិភពលោកតែម្តង គឺធ្វើឱ្យខូចខាតផ្នែកខាងក្រោមនៃប្រាសាទព្រះវិហារ ឆេះរូបចម្លាក់ការិយាល័យរបស់អង្គការយូណេស្កូ និងផ្សារនៅជាប់ជើងប្រាសាទព្រះវិហារ ដែលក្នុងហេតុការនោះធ្វើឱ្យពលរដ្ឋខ្មែរប្រមាណ500 គ្រួសារបង្ខំចិត្តចាកចេញពីភូមិដែលធ្លាប់រស់នៅជាបណ្តោះអាសន្ន។

តាមសេចក្តីរាយការណ៍បានឱ្យដឹងថាពលរដ្ឋខ្មែររងគ្រោះទាំងនោះបានរត់ទៅស្នាក់នៅភូមិស្រអែម ក្បែរជើងភ្នំប្រាសាទព្រះវិហារ ហើយកំពុងជួបនឹងគ្រោះទុរភិក្ស ជំងឺផ្សេងៗ និងគ្មានមុខរបរសម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃដែលកំពុងតែខ្វះខាតយ៉ាងខ្លាំង ។

ទោះបីជាពលរដ្ឋខ្មែរនៅតាមជាយដែនកម្ពុជា-សៀមជួបប្រទះម្តងហើយ ម្តងទៀត ដោយសារការឈ្លានពានពីសំណាក់ទាហានសៀមក្តី ក៏នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន នៅតែបន្តការចរចាទ្វេភាគី មិនព្រមប្តឹងរឿងរ៉ាវទាំងនេះទៅអង្គការសហប្រជាជាតិឡើយ ។ ទោះបីជាមានការអំពាវនាវពីអ្នកនយោបាយ អង្គការសង្គមស៊ីវិល និងពលរដ្ឋខ្មែរទាំងក្នុង និង ក្រៅប្រទេសយ៉ាងទទូចយ៉ាងណាក្តី ។

លោក ស៊ាន ប៉េងសែ ប្រធានគណៈកម្មាធិ-ការព្រំដែនកម្ពុជា ប្រចាំប្រទេសបារាំង បានមានប្រសាសន៍ថា ហ៊ុន សែន ជាមនុស្សកំសាកមិនមានឆន្ទៈការពារទឹកដីរបស់ខ្លួនទេ ហើយ ហ៊ុន សែន បានចុះហត្ថលេខាអនុសារណៈឆ្នាំ 2000 ជាមួយអតីតលោកនាយករដ្ឋមន្ត្រី ថាក់ ស៊ីន ស៊ីណាវ៉ាត្រា រឿងព្រំដែននេះ ធ្វើឱ្យកម្ពុជាខូចប្រយោជន៍ និងបន្តឱ្យសៀមមានឱកាសចូលទឹកដីខ្មែរនៅពេលនេះ ។

លោក ស៊ាន ប៉េងសែ បានបន្តថា បញ្ហា ដែលមានប្រសិទ្ធភាពនេះ គឺមិនត្រូវចរចាទ្វេភាគីនោះទេ ត្រូវតែប្តឹងទៅអង្គការសហប្រជាជាតិជាបន្ទាន់ បើពុំនោះទេសៀមវាមានឱកាសឈ្លានពានទឹកដីកម្ពុជាស្រប់ច្បាប់ហើយ ។

គួរបញ្ជាក់ថា ចាប់តាំងពីមានព្រឹត្តិការណ៍ផ្ទុះអាវុធកាលពីខែកក្កដា ឆ្នាំ2008មក សៀមបានបញ្ជូនទាហានរបស់ខ្លួនមកកាន់ព្រំដែនកម្ពុជានៅគ្រប់ទីកន្លែង តាំងពីខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យព្រះ-វិហារ ។ ជាពិសេសនោះ ពួកទាហានសៀម បានចូលមកកាន់កាប់លើទឹកដីខ្មែរនៅតំបន់មួយចំនួនមិនគោរពតាមកិច្ចព្រមព្រៀង សន្ធិសីទទីក្រុងប៉ារីស ថ្ងៃទី 23 តុលា 1991 និងផែនទីឆ្នាំ 1904 និង 1908 ដែលគូរដោយ បារាំង-សៀម ឡើយ ៕







# ព័ត៌មានពីប្រទេសថៃ : វិបត្តិស្រុកថៃមិនចប់ទេ

**ដោយ : ម៉ម យិន**

•••ទោះបីជាមានការផ្លាស់ប្តូរនាយករដ្ឋមន្ត្រីជា ច្រើនដងមកហើយ យ៉ាងណាក៏ដោយ ក៏វិបត្តិនយោបាយថៃ នៅតែបន្ត គឺប្រៀបដូចជាគ្រាន់តែប្តូរវេណគ្នា សំរាប់បង្ហាញមតិពិភព



–លោកឱ្យមើលឃើញថា នៅក្នុងប្រទេសថៃ កំពុងមានការអនុវត្តន៍គោលការណ៍លទ្ធិប្រជាធិបតេយ្យ ដែលច្បាប់រដ្ឋធម្មនុញ្ញបានចែងទុកមកតែប៉ុណ្ណោះ ។

**មូលហេតុនៃវិបត្តិ :** កាលពីសម័យរដ្ឋាភិបាលលោក តាក់ស៊ិន មានក្រុមប្រឆាំងដ៏ខ្លាំងក្លាមួយ មានឈ្មោះថា ក្រុមអាវលឿង បានធ្វើបាតុកម្មមហាជនយ៉ាងខ្លាំងក្លា ដោយសន្តិវិធីអហឹង្ស ពុំមានប្រើអាវុធ វាយកំទេច ឬផុតបំផ្លាញអ្វីទេ មានន័យថា ជាមហាបាតុកម្មមានរបៀបរៀបរយ ។

លុះមកដល់សម័យ រដ្ឋាភិបាលដឹកនាំដោយលោក អភិស៊ិត វេឆាជីវ៉ាក់ ដែលពីមុនជាគណបក្សមានអាសនៈតិចនៅក្នុងរដ្ឋសភាត្រឡប់ទៅជាបានក្លាយទៅជាគណបក្សមានអំណាចបង្កើតរដ្ឋាភិបាលថ្មីទៅវិញ រួចហើយមានគាំទ្រពីក្រុមប្រឆាំងអាវលឿងផងដែរ ។ ហេតុការណ៍នេះបណ្តាលឱ្យក្រុមនិយមលោក តាក់ស៊ិន និងលោក តាក់ស៊ិនផ្ទាល់ ដែលកំពុងនិរទេសខ្លួននៅក្រៅប្រទេស ចងកំហឹងយ៉ាងខ្លាំង ហើយបង្កបង្កើតឱ្យមានមហាបាតុកម្មមហាជនអាវក្រហមឆ្និនឆ្នៅនេះឡើង ។

មេមហាបាតុកម្មក្រុមអាវក្រហម បានចេញមុខប្រកាស និងអំពាវនាវឱ្យមហាជនទូទៅទាំងប្រទេសក្រោកឡើងចូលមករួបរួមគ្នា ដើម្បីផ្តួលរំលំរដ្ឋាភិបាលថ្មី រួចហើយទៅដង្ហែរលោក តាក់ស៊ិន ឱ្យមកដឹកនាំប្រទេសថៃជាថ្មីឡើងវិញម្តងទៀត ហើយគោលការណ៍ចំបងចង់រំលាយពួករាជានិយមចោលទៀតផង ដោយប្រើពាក្យចោទប្រកាន់ថា " ស្តេចកំពុងអនុវត្តន៍គោលការណ៍លទ្ធិអាមាត្យធិបតេយ្យ " គឺសំដៅទៅលើក្រុមអង្គមន្ត្រីគ្រប់រូបរបស់ស្តេច ដែលមានលោកឧត្តមសេនីយ៍ ប្រេមទិនសុឡានន់ ជាប្រធាន ។

ដោយសារតែលោក តាក់ស៊ិន បានក្រាសពីចម្ងាយចេញមុនជាមេទ័ពមហាបាតុកម្មក្រុមអាវក្រហមនេះ បានបណ្តាល ឱ្យក្រុមអ្នកគាំទ្របានបង្កើនឡើងជារៀងរាល់ ថ្ងៃទូទាំងប្រទេសដោយមានផែនការត្រូវតែផ្តួលរំលំរដ្ឋាភិបាលលោក អភិស៊ិត នេះឱ្យបានសម្រេចជោគជ័យ ។ លើកនេះ ក្រុមអាវក្រហម បានចេញមកធ្វើបាតុកម្មជាសកម្មភាពកាន់តែខ្លាំងឡើងៗ ដោយមានអំពើហឹង្សា ដែលផ្ទុយពីពេលមុនៗ តួយ៉ាងជាក់ស្តែងបានបង្ហាញច្បាស់នៅមុនថ្ងៃធ្វើបុណ្យសង្ក្រាន្តចូលឆ្នាំថ្មី ចំនួន ៤ថ្ងៃ គឺពីថ្ងៃទី៨ ខែមេសា ដល់ថ្ងៃទី១២ ដែលរដ្ឋាភិបាល និងប្រជាពលរដ្ឋថៃ ចាត់ទុកជាថ្ងៃមហាវិនាសកម្ម ដែលកើតចេញមកពីក្រុមអាវក្រហមនិយមលោក តាក់ស៊ិន ។ ថ្ងៃទី៨ ខែមេសានេះ មហាបាតុកម្ម ដោយអំពើហឹង្សាបានកើតឡើង បាតុករបានទៅប្រមូលផ្តុំគ្នា នៅតាមចំណុចផ្លូវបំបែកធំៗ បិទខ្ទប់ផ្លូវចរាចរសំខាន់ៗ ទៅកាន់មន្ទីរពេទ្យធំៗ និងមន្ទីររដ្ឋបាលសាធារណៈសំខាន់ៗ ស្ទើរគ្រប់ទីកន្លែងនៅក្នុងទីក្រុងបាងកក រួចហើយកំហឹងខ្លាំងក្លាមួយ បានកើតឡើងនាថ្ងៃនោះ គឺនៅពេលដែលលោកនាយករដ្ឋមន្ត្រី អភិស៊ិត ចេញពីប្រជុំគោចរនៅសណ្ឋាគារមួយនៅក្រុង ប៉ាតាយ៉ា មាត់សមុទ្រ ក្រុមក្បួនរថយន្តលោក អភិស៊ិត ត្រូវបានក្រុមអាវក្រហម មានប្រមាណជាង ២០នាក់ បានចោមរោម មានគម្រោងចាប់លោកនាយករដ្ឋមន្ត្រី ធ្វើឱ្យមានការជ្រួលច្របល់ ព្រួយបារម្ភដល់សុវត្ថិភាពលោកនាយក ។

**លទ្ធផលនៃថ្ងៃវិនាសកម្ម ៤ ថ្ងៃ**

ដោយសារតែផែនការនេះ បានចេញពីលោក តាក់ស៊ិន ដោយផ្ទាល់ ទើបបណ្តាលឱ្យមានស្ថានភាពយ៉ាងគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំងខ្លាចក្រែងតែមានអំពើហឹង្សាផ្ទុះឡើងរហូតដល់មានការបង្ហូរឈាមគ្នាជាសង្គ្រាមក្នុងស្រុក ។

ក្រុមអាវក្រហម បានចាប់ផ្តើមបញ្ចេញសកម្មភាព គួរឱ្យភ័យខ្លាចនៅក្នុងចំណុចគោលដៅសំខាន់ៗ ជាពិសេសនៅក្រុងប៉ាតាយ៉ា ដែលរដ្ឋាភិបាលមានភារកិច្ចត្រូវរៀបចំការប្រជុំប្រទេសបក្សអាស៊ានបូក៣ ឬបូក៦ ។

ទិដ្ឋភាពដ៏ហឹង្សា ឃោឃៅរបស់ក្រុមអាវក្រហម នាក្រុងប៉ាតាយ៉ា គឺស្ថានភាពចលាចលបានផ្ទុះឡើង មានការ វាយប្រហារទៅលើក្បួនរថយន្តលោកនាយករដ្ឋមន្ត្រី សហការីរដ្ឋបាលមួយចំនួនមានរងរបួសជាទម្ងន់ រថយន្តជាច្រើន គ្រឿងត្រូវវាយកំទេច ឬផុតបំផ្លាញស្នូរសម្រែកប្រឆាំងលាយដោយស្នូរ អាវុធ បានលាន់ឮឡើង ធ្វើឱ្យទីក្រុងទេសចរណ៍ ប៉ាតាយ៉ា ស្ទើរក្លាយទៅជាសមរភូមិមួយទៅហើយ ។

សកម្មភាពក្រុមអាវក្រហម ចេះតែបន្តទៅទៀត ដូចជាចាប៉ីរបអូសយករថយន្តក្រុង ចាប់រថយន្តដឹកប្រេងសាំង ការវាយកំទេចមន្ទីររដ្ឋបាល ការគម្រាមកំហែងវាយកំទេចទីស្នាក់ការធំគណបក្សប្រឆាធិប៉ាត់ និងក្រសួងមហាផ្ទៃជាដើម ។

**វិធានការបង្ក្រាបរបស់រដ្ឋាភិបាល**

ដោយចង់ជៀសវាងការបង្ហូរឈាមគ្នារដ្ឋាភិបាល បានប្រកាសអំពាវនាវដល់មហាបាតុករអាវក្រហមឱ្យបំបែកគ្នាទៅកាន់ទីលំនៅវិញទៅ ប៉ុន្តែមហាបាតុករមិនបានគោរពតាមការប្រកាសនោះឡើយ ទើបបណ្តាលឱ្យកងទ័ពជាតិថៃទទួលបញ្ជាឱ្យចេញមកបំបែកហ្វូងបាតុករ ដោយប្រើគ្រាប់បែកផ្សែងបង្ហូរទឹកភ្នែក និងបាញ់កាំភ្លើងដៃ (តទៅទំព័រទី១៨)


# ឱសថស្ថាន ផ្លូវលេខ 8

## វេជ្ជបណ្ឌិត អាឡិច លឿង

**8th Street Pharmacy**

Alex. N. Luong, RPh.

OPEN HOURS:
Mon. – Fri.: 9:00AM – 7:00PM
Sat.: 9:00AM – 5:00PM
Sun.: 9:00AM – 3:00PM

បើចង់បានសេវាថ្នាំពេទ្យឆាប់ សូមអញ្ជើញមករកអ្នកភូមិរបស់អ្នក គឺឱសថស្ថាន ផ្លូវលេខ ៨ ( ជ្រុងផ្លូវលេខ៨ និង CHRISTIAN ហ្វីឡា-ខាងត្បូង)

☛ យើងទទួលប័ណ្ណមេឌីប៊ែរ នឹងមេឌីខេត

▸ **We Do accept Medicare & Medicaid**

▸ **We Do Offer Alternative Natural Medicines Including:**

☛ យើងមានផ្តល់ជូននូវឱសថធម្មជាតិ មានដូចជា :



- Prostate -7 – ជួយដល់សុខភាព "ប្រស្តេដ" ដល់បុរស
- Pure Fresh Royal Jelly – ជួយលើកដំកើងនូវរសជាតិនៃជីវិត
- Fe-mon-9 – ជួយដល់ស្ត្រីនៅពេលមានអ័រម៉ូន
- Super Cross – ជួយបន្ថយការតាំងបេះដូង,ការលើសឈាម ឬកូឡេស្តេរ៉ុលច្រើន
- Gold Medal Swiss Placenta "សុកពពែស្វីស" មេដាយមាស សំរាប់កែសម្ផស្ស

819 S. 8th St.
Philadelphia, Pa 19147
Phone: 215-592-8888
Fax: 215-592-9888




# ក្ដីស្នេហ៍គ្មានទីបញ្ចប់

**ដោយ : គឹម ភឿន**

**(តពីលើកមុន)**

•••បងច្បាស់ជារង់ចាំនារីម្នាក់ដែលបងស្រឡាញ់ទៅទទួលបង ពេលបងចុះពីយន្តហោះ បុប្ផាយល់ចិត្តបងច្បាស់ណាស់ពេលដែលអត់ឃើញរូបអូន ។ បុប្ផាក៏មានចិត្តអន្ទះសាមិនខុសពីបងទេ ពេលមិនបានទៅទទួលបងនៅថ្ងៃនេះ ។ អូនរង់ចាំបងពីមួយថ្ងៃទៅមួយថ្ងៃ ពេលវេលាសម្រាប់អ្នករង់ចាំ ពិតជាយូរណាស់ តែចុងក្រោយបំផុត វាត្រូវតែមកដល់ សម្រាប់អ្នកមានអំណត់ ។ សូមអបអរការវិលមកវិញរបស់បងពីនារីម្នាក់ដែលបានរង់ចាំ ដែលរាប់ទាំងខែទាំងថ្ងៃទាំងម៉ោង... រដូវផ្កាក្ងោករីកហើយរោយហើយលាស់ស្លឹកខ្ចី ហើយផ្កាក្ងោករីកក្រហមឆ្អៅម្តងទៀត នៅតែមិនឃើញបងមកសមនឹងកំណាព្យមួយដែលបងសរសេរមកឱ្យអូនថា :

ពេលបងចេញទៅផ្កាក្ងោករោយ
ផ្ការីកឆ្នាំក្រោយមិនទាន់មក
យើងត្រូវរង់ចាំពិតវិយោគ
ចំណងទុក្ខសោកយើងទាំងពីរ ។
ចំណងក្តីស្នេហ៍ពិតមានន័យ
បែកឆ្ងាយអាល័យតែសង្ឃឹម
ពេលទឹកដល់អូនបងញញឹម
ឋានសួគ៌បម្រើមរង់ចាំយើង ។

ថ្ងៃបងវិលវិញដែលអូនរង់ចាំយ៉ាងអន្ទះសា នោះបានមកដល់ហើយ តែការដែលធ្វើឱ្យអូនខកខានពុំបានទៅទទួលបងនោះ ចាំអូនជម្រាបបងនៅពេលក្រោយ ចាំបងមានឱកាសមកលេងអង្គតាសោម បងនឹងបានជ្រាប ។ ជីវិតមានភាពស្ងប់ស្ងាត់ដូចផ្ទៃទឹកបឹងស្ងប់ខ្យល់ នៅក្នុងរដូវស្លឹកឈើជ្រុះនោះទេ តែទោះជាខ្យល់បក់បោករលកប្រដេញមកផ្ទប់ច្រាំងម្តងហើយម្តងទៀតក៏ដោយ គង់មានខ្យល់ស្ងប់ទៅវិញ ឱ្យតែយើងមានក្តីអំណត់រង់ចាំ... សូមបងខំថែខ្លួន ឱ្យបានសុខ សូមឱ្យមានជ័យជំនះគ្រប់វិស័យគ្រប់ ភារកិច្ច ។

ពីនារីម្នាក់ដែលពុំចេះនឿយណាយរង់ចាំបងកល្យានបុប្ផា !

អានសំបុត្រចប់ភ្លាម ខ្ញុំហាក់ដូចងងិតមុខស្លុប វិលមុខចង់ដួល មិនដឹងមានអីកើតឡើង ខ្ញុំខំសញ្ជឹងគិតមិនយល់ នូវឃ្លាដែលនាងសរសេរ



នោះទេ ។ វាហាក់ដូចជាមានអាថិកំបាំងអ្វីដូចជាឃ្លាថា :

-ទន្ទឹងផ្លូវណាស់តែពុំបានមកជួបបងពេលបងបានមកវិញ ? -គង់មានពេលខ្យល់ស្ងប់ទៅ វិញឱ្យតែយើងមានក្តីអំណត់រង់ចាំ ? -ពីនារីម្នាក់ ដែលមិនចេះនឿយណាយរង់ចាំបង ? នាងកំពុងនិយាយអីហ្នឹង ? មានរឿងអីទៅកល្យានបុប្ផាអើយ ? ម៉េចអូនមិនព្រមនិយាយឱ្យចំៗមក ? បងមកដល់ស្រុកហើយ ម៉េចបែរជាមានរឿងហេតុអីអូនមិនព្រមនិយាយឱ្យបងដឹងច្បាស់មក ? ។

អារម្មណ៍កំពុងតែវិលវល់ស្រាប់តែអ្នកបើកបរតាក់ស៊ីបានរំលាយអារម្មណ៍នេះយ៉ាងរហ័ស

- លោកមានអ្នកណាមកទទួលឬទេ ? ខ្ញុំភ្ញាក់ ពីអារម្មណ៍ដើរទេសន៍មកបច្ចុប្បន្នភ្លាម ហើយ ញញឹមរកប្អូនតាក់ស៊ី

-ឱមែន ប្អូនចាំជូនខ្ញុំមែនទេ ? ល្អណាស់ខ្ញុំកំពុងតែអត់មានអ្នកណាមកទទួលផង ប្អូនជួយយកខ្ញុំទៅដាក់វត្តលង្ការ ថ្វាយបង្គំលោកគ្រូខ្ញុំសិន ហើយចាំសរសេរសំបុត្រខ្លីមួយតបទៅអរគុណអ្នកគ្រូបុប្ផាផង ! ។ តាក់ស៊ី ក៏បោះពួយកាត់ផ្សារពោធិ៍ចិនតុងតម្រង់រដ្ឋធានីភ្នំពេញយ៉ាងលឿន តែត្រូវបង្អង់ ហើយឈប់ស្ងៀមនៅកន្លែងរបងលួសបន្លាកាត់ផ្តល់ម្តងៗ (បារ៉ាស់) ដើម្បីការពារ

ខ្មាំងជ្រៀតចូលភ្នំពេញបង្កការអុកឡុក ។

ឱភ្នំពេញជាទីស្រឡាញ់អើយ បែកពីអ្នកជាងមួយឆ្នាំ អ្នកផ្លាស់ប្តូរច្រើនណាស់ ធ្លាប់តែសន្តិភាព ធ្លាប់តែមនុស្សម្នាមានទឹកមុខរីករាយឥឡូវមិនឃើញទៀតទេ ! ទឹកមុខទុក្ខព្រួយអស់សង្ឃឹមបានចេញមកជំនួសវិញ ។ ដីទឹកនគរខ្មែរកាត់ជាចំណែកជាដុំលុះដោយអំណាចលោកសេនាប្រមុខប្រធានាធិបតី ឬក៏បក្សពួកគាំទ្រសម្តេចឪ ។ តែទាំងសងខាងសុទ្ធតែមានយួនជាអ្នកលើកទឹកចិត្តជាអ្នកបំផ្លាញស្រុកខ្មែរដោយស្របច្បាប់ ។

កម្ពុជាស្រុកខ្ញុំមានកម្មក្រាស់
សុខមានតិចណាស់ឃើញតែទុក្ខ
តំណពីនេះទៅថ្ងៃមុខ
កម្មពារម្ចាស់ស្រុកពេលណាស្បើយ? ។
ព្រោះតែរឿងគេនាំគ្នាច្បាំង
កាប់ចាក់យកខ្លាំងតែសព្វកាយ
ឈាមខ្មែរពេលនេះត្រូវហូរខ្ចាយ
កេរ្តិ៍ខ្មែររលាយម្តងទៀតហើយ ។
សមខ្មែរពេលនេះនឹងសាបសូន្យ
ព្រោះខ្មែរភ្លេចក្បួនពីបុរាណ
សាមគ្គីគីរស់ខ្លាំងក្លាហាន
បែកបាក់ភូមិឋានត្រូវរលាយ ។

កំពុងតែលន្លង់អន្លោចមមៃគិតដល់ភាពរង់កម្មនៃមាតុភូមិ នៃសាច់ញាតិ ជនជាតិខ្មែរអភ័ព្វរបស់ខ្លួន ស្រាប់តែតាក់ស៊ីបាននាំខ្ញុំមកដល់វត្តលង្ការ ដោយពុំបានស្មានទុកមុន ។ អ្នកបើកបរបានមកចតក្បែរជណ្តើរកុដិមួយ នៅខាងត្បូងព្រះវិហារ ។ នាយបើកបរវ័យក្មេងបានជួយយួរអីវ៉ាន់កំបិកកំបុករបស់ខ្ញុំឡើងទៅលើកុដិ ហើយក្រាបថ្វាយបង្គំលោកតាខ្ញុំ ព្រមទាំងព្រះសង្ឃដទៃដែលបានគង់រង់ចាំទន្ទឹងមើលផ្លូវខ្ញុំនៅលើកុដិ ។ បន្តិចក្រោយមកខ្ញុំបានបញ្ចប់សំបុត្រមួយដោយសង្ខេបសម្រាប់នារីជាទីស្រឡាញ់នៃជីវិតខ្ញុំ រួចហើយហុចទៅឱ្យអ្នកបើកបរវ័យក្មេងមានឈ្មោះ ច្រក នោះព្រមទាំងសោហុយបន្តិចបន្តួចផង " នែប្អូន ច្រក សូមប្អូនមេត្តាជួយយកសំបុត្រនេះជូនអូនបុប្ផាផង ហើយនេះលុយបន្តិចបន្តួចយកទៅចាក់សាំងចុះណ៎ា !។ នាយបើកបរតាក់ស៊ីទទួលយកសំបុត្រ ហើយបែរជាហុចលុយសងមកវិញ ដោយទឹកមុខរីករាយឆ្លើយថា " អរគុណហើយលោក អ្នកគ្រូបានឱ្យលុយខ្ញុំចាក់សាំងគ្រប់គ្រាន់ហើយ ខ្ញុំសុំលាលោកទៅអង្គតា-សោមវិញហើយ " ។ អ្នកកម្លោះចុះពីកុដិបណ្តើរយកសំបុត្រញាត់ចូលក្នុងសំពាត់យួររបស់ខ្លួនបណ្តើរ ហើយចូលទៅក្នុងតាក់ស៊ីបរចេញបាតទៅ ។

**សូមរង់ចាំអានភាគបន្ត )**

Washington Wellness Care

●បើលោកអ្នកមានគ្រោះថ្នាក់រថយន្ត, មានរបួសនៅកន្លែងធ្វើការ ឬក៏រអិលហើយដួលរហូតដល់មានរបួសតែពុំដឹងនរណាជា អ្នកទទួលខុសត្រូវ ?






●យើងអាចជួយលោកអ្នកបាន

●មជ្ឈមណ្ឌល "វ៉ាស៊ីនតុនវែលណេសឃែ" មានបទពិសោធន៍ក្នុងរឿងរបួសក្នុងគ្រោះថ្នាក់រថយន្ត មានរបួសនៅកន្លែងធ្វើការនឹងរអិលដួលបណ្តាលឱ្យរបួស
●យើងណែនាំទៅមេធាវីដែលអាចការពារសិទ្ធិលោកអ្នកបាននៅពេលមានគ្រោះថ្នាក់
●អាចផ្តល់ផែនការណ៍ជួយចេញសោហ៊ុយចំពោះបុគ្គលដែលគ្មានប័ណ្ណធានារ៉ាប់រង
●សូមទូរស័ព្ទមក "វ៉ាស៊ិនតុនវែលខែល" ភ្លាម ដើម្បីឱ្យដឹងថា តើយើងអាចជួយលោកអ្នកដោយវិធីណា

វិតី និយាយភាសាខ្មែរ លេខទូរស័ព្ទ : 215-380-1350

500 Washington Ave., 1st Fl. Philadelphia, Pa 19147 Phone: 215-551-6838

# ថ្ងៃ១៧ មេសា ឆ្នាំ ១៩៧៥

ជាថ្ងៃខួបនៃជ័យជំនះខ្មែរកុម្មុយនិស្ត នៅកម្ពុជា តែជ័យជំនះ បែរជាធ្វើឱ្យខ្មែរ និងប្រជាពលរដ្ឋពិភពលោក ចងចាំពីវិនាសកម្ម ដោយសារការចងគំនុំនឹងប្រជាជាតិខ្លួនឯងយ៉ាងធំធេង ។ នៅរដ្ឋធានីវ៉ាស៊ីនតុនពលរដ្ឋខ្មែរនាំគ្នារួមប្រជុំនៅក្នុងឧទ្យានសាធារណៈមួយឈ្មោះ ឡាហ្វាយ៉ែត នាយប់ថ្ងៃទី ១៧ មេសា នោះ ដើម្បីអុជទាននៅមុខសេតវិមានប្រធានាធិបតីអាមេរិកាំង ដើម្បីឱ្យប្រជាជាតិពិភពលោកជួយចងចាំទិវាដែលក្រុមខ្មែរកុម្មុយនីស្តបានធ្វើទារុណកម្មលើពលរដ្ឋខ្លួនឯង បណ្ដាយឱ្យស្លាប់មនុស្ស ២ លាននាក់ ។

យុវនារី ម្នាក់ ឈ្មោះ ណារី គីត បានសាកល្បងសរសេរពីទឹកចិត្តរបស់នាងចំពោះឱកាសនោះ ។



**Remembering the Lives... By Nary Kith**




On April 17, 1975, The Khmer Rouge was victorious and celebrations were under way when the Cambodian civil war came to an end after 8 years (1967-1975) of atrocities. The ending of the civil war gave hope that Cambodia would be restored and at that moment it did not matter whether you supported the Khmer Rouge troops rather the focus shifted to supporting the idea that Cambodia would finally have peace.

The fall of the Khmer Republic on April 17, 1975 opened up opportunities for the Khmer Rouge to control every aspect of Cambodia. So as people celebrated on that day feeling more hopeful that their country would have peace; the Khmer Rouge entered and killed the hopes and dreams of their land ever being free. Cambodia's 2000 years of history, culture and traditions were wiped away and on that celebratory, sunny yet gloomy day, there was a new Cambodia: Democratic Kampuchea (DK) and it was the beginning of the year zero; the beginning of an end.

People of Cambodia were forced out of their homes and into labor camps, families were separated, people were categorized according to "old people" and "new people". Old people were spared immediate death because they were useful in the labor camps and because many of them were uneducated, they were less likely to fight against the new Cambodia. The new people (also called "April 17" people) lost their lives for the mere fact that their education and political ideologies were seen as threatening to the success of DK. No matter if they were categorized as old or new people; they were learning how to survive because the Khmer Rouge terroristic mind set and hunger for control executed people for no reasons at all. People were sent to the "killing fields" if they laughed, smiled, looked at someone, or questioned the new ideologies. So the new people (doctors, teachers, and educators) cut ties with their past life with the hopes that they would live to see their next hour. And the old people did exactly what they were told with the hopes that they would be reunited with their families and would no longer have to face starvation, abuse or death. The Khmer Rouge was so powerful that they were able to manipulate and brainwash children against their parents. The Khmer Rouge was on a mission to convert Cambodia into a communist state.

People who were spared their lives survived by holding on to their faith and hope that one day Cambodia will thrive and persevere against all odds. Despite the starvation, the brainwashing, the emotional, mental and physical suffering, the people of Cambodia, new and old, were determined to live. Whatever it was that kept their hope alive was instrumental in helping to re-build Cambodia as it is today. And although the war has ended, Cambodia still struggle with building a free state due to corruption, greed and power.

The Khmer Rouge reign of terror ended in January 1979 but the devastation lives on. Even after 33 years, the painful memories of a horrific era continue to haunt the survivors who endured unspeakable torture during the Khmer Rouge Regime. It is everyday and especially on April 17 that survivors re-live their trauma and remember the day that the Khmer Rouge troops entered Cambodia and it is on this day that they remember the 1.7 million lives lost during the four year reign of a terrorist group.

**continued to next issue...**

ART OF WELLNESS CENTER



Art of Wellness
"Integrating Holistic Healthcare for the Mind, Body, and Spirit."
(215)305-2238
www.artofwellnesscenter.com



មន្ទីរសុខភាព "Art of Wellness" ទទួលព្យាបាលបញ្ហាផ្លូវចិត្តនឹងកាយធ្វើទៅតាមទម្លាប់ និងជំនឿរបស់លោកអ្នក របៀបបច្ចេកទេស និងបច្ចេកវិទ្យាបច្ចិមប្រទេស ។

ចំពោះលោកអ្នកមានការលំបាកណាមួយដូចចំណុចខាងក្រោម:

- ធ្លាក់ទឹកចិត្ត DEPRESSION
- ការថប់អារម្មណ៍ ANXIETY
- ភាពតានតឹង STRESS
- មានកំហឹងច្រើន ANGER MANAGEMENT
- ឈឺខ្លួនប្រាណគ្រប់កន្លែង PAIN MANAGEMENT
- មានវិបត្តិក្នុងគ្រួសារ FAMILY ISSUES
- ការញៀន និងអ្វីមួយ ADDICTION ISSUES
- សុខភាពស្ត្រី WOMEN'S HEALTH

ទទួលព្យាបាលបានគ្រប់វ័យ

| របៀបព្យាបាល | TREATMENT TYPE |
|---|---|
| ប្រើម្ជុលឥតថ្នាំ | Acupuncture |
| ចាប់សរសៃ | Acupressure |
| ចិត្តវិទ្យា | Psychotherapy |
| យោគ/ ភាវនា | Yoga / Meditation |

វេជ្ជបណ្ឌិតនិងអ្នកជំនាញការមានបទពិសោធន៍ច្រើនឆ្នាំ នៅប្រទេសចិន និងនៅសហរដ្ឋអាមេរិក ។

សូមអញ្ជើញទូរស័ព្ទ ឬមកមន្ទីរពេទ្យសុខភាពយើងខ្ញុំ ដើម្បីពិគ្រោះវិធីព្យាបាល

ART OF WELLNESS CENTER
647 BAINBRIDGE SREET
PHILADELPHIA, PA 19147
215-305-2238
ភាសាខ្មែរទាក់ទង ប៊ុន គីត : 267-242-8526

តមកពីទំព័រទី ០២

# មានអ្វីប្លែកនៅឆ្នេរខាង...

ថ្ងៃ អាទិត្យ ទី២៦ មេសានេះ ភ្ញៀវខ្មែរ និងអាមេរិកាំងប្រមាណ២០០នាក់ បានប្រជ្រៀតគ្នាមកអបអរសាទរការសម្តែង "របាំហនុមាន " ដោយក្រុម Hip Hop ខ្មែរ មានគ្នា៧នាក់ មានអាយុពី ១៤ ដល់ ២៣ឆ្នាំ ។ ធី បួយ ជាមេក្រុម, ដាយ ម៉ុន ជាយុវនារីតែម្នាក់ក្នុងជួរ, សុខា, សូសាយ, ក្តិប, ចេញសម្តែងជាង១ម៉ោង ដោយប៉ិនប្រសព្វ ហើយចំណេះនេះបានមកពី តូនី ដែលជាគ្រូបង្ហាត់ត្រឡប់ពីសហរដ្ឋអាមេរិក ជាមួយនឹងកូនខ្មែរ ចំនួនជិត២០០នាក់ ដែលសហរដ្ឋអាមេរិក បានដាក់ទោសនិរទេស ដោយការប្រព្រឹត្តខុសច្បាប់ ។

នៅក្នុងវេបសាយ " តូនី ទូន " គេបានរៀបចំពីជីវិតនៅកម្ពុជា របស់ តូនី នៅពេលទៅដល់កម្ពុជា គ្មានបងប្អូនទទួលទាំងមិនចេះភាសាខ្មែរ ហើយមិនដែលកើតនៅស្រុកខ្មែរទៀតផង ។ តូនី ឥឡូវនិយាយថា "ស្រុកខ្មែរជាផ្ទះរបស់ខ្ញុំ " ហើយមានកន្លែងឱ្យកុមារ និងយុវជនមាន ឬគ្មានទីពឹងមកហាត់រៀនរបាំ Hip Hop ដែលកំពុងពេញនិយមនេះ ។ រសៀលថ្ងៃអាទិត្យ ទី២៦ នេះ យុវជន យុវតី ទាំង ៧នាក់ បានបង្ហាញវប្បធម៌អាមេរិកាំង ទៅដល់អ្នករស់នៅសហរដ្ឋអាមេរិក តាមរយៈកូនខ្មែរ ដែលបានរៀនវប្បធម៌នេះ នៅកម្ពុជា ។

តាមរយៈការណែនាំរបស់សមាគមខ្មែរ ម្ចាស់អាគារសិល្បះឯកជនខ្មែរ ធំមួយនេះ គឺបូណា វ៉ាយស្តាញ បាននិយាយថា " ខ្ញុំទទួលក្រុម ហីប ហុបខ្មែរ ឱ្យសម្តែងក្នុងមណ្ឌលសិល្បះខ្មែរ ដោយ





ឥតរុញរា ដោយខ្ញុំមើលឃើញតម្លៃនៃការខិតខំប្រឹងប្រែងនៃកូនខ្មែរទាំងនោះ គួរតែត្រូវទទួលការជ្រោមជ្រែង " ។

បូណា គិតមិនខុសមែន ហីប ហុប អាមេរិកកូនកាត់ខ្មែរ បានពង្រឹងស្មារតីអ្នកដែលផ្ទង់អារម្មណ៍ហ៊ឹកហ៊ឺនទូវអ្វីដែលខ្លួនស្រឡាញ់ពេញចិត្ត ឱ្យអាចរៀនសូត្រមុខវិជ្ជាអ្វីៗទៀតបានប្រសើរ ។ "ការលើកដំកើនចំណាង់ចំណូលចិត្តរបស់យុទ្ធជន និងជួយដល់ការអប់រំ " តូនី បានធ្វើឱ្យសម្រេចផលខ្លះហើយនៅឯកម្ពុជា រីឯនៅសហរដ្ឋអាមេរិកនេះវិញ សមាគមខ្មែរ និងមណ្ឌលសិល្បះខ្មែរ នាំគ្នាំពង្រីកការលើកទឹកចិត្តឱ្យទៅយុវជន យុវតី កូនខ្មែរ នៃសហរដ្ឋអាមេរិកនេះទៀតផង ។

ថ្ងៃចន្ទ ទី២៧ នេះ អ្នកទាំង ៧នាក់ នឹងទៅបង្ហាញខ្លួននៅសាលា FELS H.S និង សាលា E3 Center នៅភាគខាងជើងនៃហ្វីឡាដែលហ្វៀ ។ សាលានោះ ត្រូវការគំរូ និងការគាំទ្រយ៉ាងខ្លាំង ដើម្បីទាក់ទាញឱ្យសិស្សទៅសាលារៀនឱ្យបានទៀតទាត់វិញ ។

**៣-អតីតយុទ្ធជន**

អតីតយុទ្ធជនខ្មែរ ចំនួន ៣០នាក់ កំពុងហាត់សមជើងក្នុងឯកសណ្ឋានកងទ័ព ដើម្បីចូលរួមក្នុងពិធីបំពាក់ស័ក្តិជាកិត្តិយស នៅថ្ងៃសៅរ៍ ទី២ ឧសភា ខាងមុននេះ ។ ចូលជាសមាជិកនៃអគ្គមេបញ្ជាការដ្ឋាននៃយុទ្ធជនស្ម័គ្រចិត្ត អតីតយុទ្ធជនជំនាន់សាធារណរដ្ឋ និងអតីតយុទ្ធជនតស៊ូអតីតយុទ្ធជនខ្មែរកម្ពុជាក្រោម បានទទួលសិទ្ធិឱ្យអាចមានឋានន្តរស័ក្តិរបស់ខ្លួន មានអត្តសញ្ញាណប័ណ្ណថ្មី ពីអគ្គមេបញ្ជាការឡើងវិញ ។

នៅក្នុងឯកសណ្ឋានកងទ័ព អតីតយុទ្ធជនមានទឹកមុខស្រស់បស់ ហើយប្រឹងហាត់យ៉ាងស្វាហាប់ រីងប៉ុងប្រហែលគ្នា នឹងកាលពីនៅវ័យក្មេងដូច្នេះដែរ ។

**៤- គណបក្សសិទ្ធិមនុស្ស**

គណបក្សសិទ្ធិមនុស្សនៅហ្វីឡាដែលហ្វីយ៉ាតំណាងដោយលោក ញយ ចំរើន បានអញ្ជើញសមាជិករបស់ខ្លួនមករួមប្រជុំ នៅថ្ងៃអាទិត្យ ទី ១៩ មេសា ដើម្បីតែងតាំងតំណាងក្រៅប្រទេសថ្មីរបស់ខ្លួន បន្ទាប់ពីតំណាងចាស់ គឺលោក ឈឹម សោធន់ បានលាលែងពីតំណែង ។ លោក សោធន់ បានសំដែងក្នុងលិខិតលាលែងពីការខកចិត្តថា "ក្នុងគណបក្សលោកមានអនុវត្តន៍គំនិតបក្ខពួកនិយម ហើយការគ្រប់គ្រង់ថវិកាគ្មានតម្លាភាព " ហើយលិខិតនេះបញ្ជាក់ថា លោកដកខ្លួនពីតំណែង និងគណបក្សសិទ្ធិមនុស្សជាមួយគ្នា នៅថ្ងៃចុះហត្ថលេខាលើលិខិតនេះ ។ សមាជិកចំនួន១១ តំបន់នៃសហរដ្ឋអាមេរិក និងកាណាដា បានធ្វើកិច្ចប្រជុំពិភាក្សាតាមទូរសព្ទ ហើយបានសម្តែងការគ្មានភ្ញាក់ផ្អើលពីការដកខ្លួនរបស់លោក ឈឹម សោធន់ ដោយយោងទៅតាមមតិចោទប្រកាន់មានតែម្នាក់ឯង ហើយពុំមានមូលដ្ឋាន និងភស្តុតាងច្បាស់លាស់ រីឯតំបន់ដែល លោក សោធន់ មានភាពជាតំណាងនៅញូយ៉ក ក៏សមាជិកភាពមានតែម្នាក់ឯងគត់ថែមទៀត ។



(តទៅទំព័រទី ១៩)

Nationwide

Insurance & Financial Service

សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

Business Liability Insurance — ធានារ៉ាប់រងជំនួញឈ្មួញ
Home Insurance — ធានារ៉ាប់រងផ្ទះសម្បែង
Health Insurance — ធានារ៉ាប់រងសុខភាព
Auto Insurance — ធានារ៉ាប់រងរថយន្ត
Life Insurance — ធានារ៉ាប់រងជីវិត

Discount 30% when you purchase Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

The Khmer Post Directory

East Coast Publication

Regional Editor : Pin Samkhon
Email : pinsamkhon@gmail.com
Writers : Mam Yin
Kim Phean
Im Loeurm
Bopea Chum

Advertising
Marketing Manager:
Sabane Thach
Phone : 267-253-3947
Email : sabane.thach@gmail.com

West Coast Publication

RegionalEditor : Sovannara Meach
Writers : Kim Saroeurn
Ra Neat
Sophea Rith
Mey Sampos
Chan Kosal
Sovann Rith
Phone: (562) 313-2129
Email: sovannara04@yahoo.com

## សូមប្រយ័ត្នចំពោះជំងឺ SWINE FLU

ជំងឺគ្រុនក្តៅ ឈ្មោះ " ស្វាន ហ្វ្លូ " កំពុងមាន សកម្មភាពយ៉ាងកំណាចដែលកំពុងសម្លាប់មនុស្សជិត ២០០ នាក់នៅម៉ិចស៊ីកូ, ជិត ៧០នាក់ នៅសហរដ្ឋអាមេរិក និងនៅតំបន់ឯទៀតៗជាច្រើន ។

គេពុំទាន់មានថ្នាំសម្រាប់ព្យាបាលពិតប្រាកដនៅឡើយទេ វាជាជំងឺដែលអាចឆ្លងយ៉ាងកាចសាហាវ ។

សូមប្រយ័ត្នកំប៉ះពាល់អ្វីដែលស្មោគគ្រោក ហើយឧស្សាហ៍លាងដៃបើមានកាន់អ្វីកខ្វក់ ៕



តមកពីទំព័រទី ០៩

## សេចក្តីសង្ឃឹមផ្តើមនៅវត្ត...

នៅមានសកម្មភាពមួយចំនួនទៀត ដែលសហគមន៍ខ្មែរ បានបង្ហាញភាពពេញចិត្តពីវត្តព្រះពុទ្ធវង្សី ដឹកនាំដោយ រ៉ូបឺត កុក អនុប្រធានគណកម្មាធិការវត្ត អំពីអ្នកជំនួញខ្មែរនៅផ្លូវលេខ៧ ដែលរកស៊ីតែជាមួយសហគមន៍ខ្មែរ







លាវ យួន បានត្រៀមខ្លួនបង្កើតសមាគមពាណិជ្ជករខ្មែរ ដែលនឹងបណ្តាលឱ្យផ្លូវមុខជំនួញខ្មែរទីនោះ មានសោភណ្ឌភាពប្រសើរ ហើយស្អាតល្អ មានសុវត្ថិភាពពីអំពើហិង្សានានា ហើយគ្មានគ្រឿងញៀន ឬអំពើអបាយមុខថែមទៀតនៅថ្ងៃខាងមុខ ។ នេះជាសេចក្តីសង្ឃឹម ដែលពលរដ្ឋនៅតំបន់នោះ មើលឃើញថា នឹងកើតឡើងបានជាប្រាកដដូចបំណងប្រាថ្នាដ៏មុះមុត ស្របគ្នានឹងសកម្មភាព សមត្ថភាពដែលគេជឿថា វត្តព្រះពុទ្ធវង្សីនេះ អាចធ្វើបានជាប្រាកដដូចគ្នា ។

នៅឱកាសចូលឆ្នាំខ្មែរលើកនេះ ថ្វីត្បិតតែសេដ្ឋកិច្ចនៃសហរដ្ឋអាមេរិក ពុំទាន់បង្ហាញចលនា វិជ្ជមានណាមួយនៅឡើយទេនោះ តែសហគមន៍ ខ្មែរភាគខាងត្បូងហ្វីឡាដែលហ្វីយ៉ា កំពុងឃើញ វត្តព្រះពុទ្ធវង្សី សងគុណអ្នកគាំទ្រខ្លួនផ្តល់នូវប្រយោជន៍ជូនពុទ្ធសាសនិកជនមកវិញខ្លះៗ ហើយដោយពុំរង់ចាំទៅដល់បរលោក សឹមទទួលបានបុណ្យនោះទេ ។ ព្រះមហាមោគល្លានបានសម្លាប់មនុស្សរាប់រយនាក់ ក៏នៅតែត្រូវបានទទួលជោគជ័យពីព្រះធម៌ នៅពេលបានអនុវត្តន៍ត្រឹមត្រូវតាមពុទ្ធឱវាទ នៅក្នុងជីវិតបច្ចុប្បន្នរបស់គាត់ នេះនឹងធ្វើឱ្យយើងមើលឃើញថា ចំណោះអាណាក្រ និងពុទ្ធចក្ររបស់វត្តព្រះពុទ្ធវង្សី អាចនឹងប្រោសសត្វ ឱ្យចុំចម្រើនជាប្រាកដបាន នាបច្ចុប្បន្ននេះ ៕

# គ្រួសារនិយមនៅកម្ពុជា ដែលនាំឱ្យរាំងស្ទះអភិវឌ្ឍន៍

**ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល**

●●●នៅក្នុងសង្គមខ្មែរបច្ចុប្បន្នបាន និងកំពុងតែចាក់ឫសយ៉ាងជ្រៅទៅក្នុងការដឹកនាំបែបបុគ្គល និងគ្រួសារ និយម ហើយពួកគេ បានព្យាយាមជ្រើសរើសបងប្អូនកូនក្មួយរបស់ពួកគេបម្រើការនៅតាមក្រសួង មន្ទីរ ឬកន្លែងណាដែលមានឱកាសប្រព្រឹត្តអំពើពុករលួយជាប្រព័ន្ធបានយ៉ាងងាយស្រួលព្រមទាំងយកលុយរដ្ឋធ្វើភាពមានបានផ្ទាល់ខ្លួនលើគំនរញើសឈាមរបស់ប្រជាពលរដ្ឋក្រីក្រទៀតផង ។

គេបានដឹងជាទូរទៅថា នៅក្រសួងសំខាន់ៗ ចំនួន6 ដែលរដ្ឋមន្ត្រីនៃក្រសួងនោះឱ្យប្រពន្ធ កូន ប្អូន និងក្មួយកាន់កាប់តួនាទីសំខាន់ៗ ដើម្បីមានឱកាសកិបកេងលុយរដ្ឋ ក៏ដូចជាការបង្កើនបក្ខពួករបស់ខ្លួនឱ្យកាន់តែច្រើន ហើយអាចបង្កព្យុះភ្លៀង តាមអំពើចិត្ត គឺគ្មានអ្នកហ៊ានតវ៉ានោះទេ ។


លោក ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


គាត ឈុន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

ទោះបីជាមានច្បាប់ហាមប្រាមមិនអនុញ្ញាតឱ្យលោករដ្ឋមន្ត្រីដែលមកពីកូតានៃគណបក្សប្រជាជនកម្ពុជាមិនឱ្យប្រព្រឹត្តអំពើផ្តេសផ្តាសក៏ដោយ ប៉ុន្តែពួកគេហាក់ដូចជាមិនសូវចាប់អារម្មណ៍ ។ ដោយសារតែពួកគេបានលាភសក្ការៈ ហើយយកទៅសូកប៉ាន់មេធំៗរបស់ពួកគេមួយជាន់ទៀត ទើបអាចបង្កព្យុះភ្លៀងបានយូរដូចសព្វថ្ងៃ ។

(តទៅទំព័រទី១៥)


**Randolph C. Smith**




Attorney at Law
267-324-6503

Office # 1
1819 JFK Blvd.
Philadelphia, Pa 19103

Office # 2
1115 S. 11th St.
Philadelphia, Pa 19147

ការិយាល័យច្បាប់យើងខ្ញុំ មានចំនាញខាងករណី គ្រោះថ្នាក់រថយន្ត
☞ ការរបួសនៅកន្លែងធ្វើការ ☞ បើកបរក្រោមឥទ្ធិពលស្រវឹង
☞ ករណីឧក្រិដ្ឋកម្ម និងអន្តោប្រវេសន៍ យើងនឹងយកចិត្តទុកដាក់ពីរថយន្តពីអ្វីទាំងអស់ដោយមិនឱ្យលោកអ្នកចំណាយប្រាក់ខ្លួនឯងឡើយ ។
បើចង់ដឹងអ្វីបន្ថែមសូមហៅរក **សុធា : (267) 324-6503**
We are specialty in Car Accident, Work Injury, DUI, Criminal Matter, and Imminration.
We will take care of your car and everything else without your pochet expense.
Please contact Sothia at 267-324-6503 for more information.

The Noni Juice



ទឹកផ្អែមផ្លែ"ណូនី"ខ្មែរហៅផ្លែ"ញ"ត្រូវគេចងចាំថា ឪពុកម្តាយ ឬជូនតា ធ្លាប់យកផ្លែ "ញ" នេះទៅត្រាំស្រា ហើយពិសារជាថ្នាំព្យាបាលការឈឺចុកចាប់នានាបណ្តាលឱ្យមានកម្លាំង-ចុះកម្លាំងឈាម ។ល។ ឥឡូវនេះ អ្នកវិទ្យាសាស្ត្រខាងពេទ្យរកឃើញថា ផ្លែ"ញ" នេះ បើប្រើឱ្យសព្វគ្មានលាយជាតិគីមីនឹងធ្វើឱ្យចុះសម្ពាធឈាមបន្ថយការឈឺសន្លាក់ដៃជើងព្យាបាលជំងឺទឹកនោមផ្អែម-ធ្វើឱ្យមានកម្លាំង និងជួយរំលាយអាហារទៀតផង។
សូមទាក់ទងតាមឈ្មោះ នឹងទូរស័ព្ទខាងក្រោម ដើម្បីជាទឹកផ្អែម"ណូនី"

Philadelphia: David: 215-268-4821 or Jason: 215-805-3396
Rhode Island: Hui Le: 401-640-5158
Lowell: Samran: 508-216-6062
The Noni Jucie is made by traditional method, 100% pure, and no preservation. It can help decrease high blood pressure; reduce arthritis pain, diabetes, increase body energy level and digestion system.

តមកពីទំព័រទី ០១ **បទសម្ភាសន៍អ្នកឃើញគេ...**

បានជួបសម្ភាសន៍ជាមួយលោក ពូ ធី អាយុ ៦៨ឆ្នាំ រស់នៅក្នុងភូមិរំលិច ឃុំលើកដែក ស្រុកកោះធំ បានអះអាងថា លោក ស៊ីន ស៊ីសាមុត ត្រូវបាន គេសម្លាប់នៅកោះកណ្ដុរ ស្របតាមចម្លើយរបស់ គ្រួសារគាត់។

**ខ្មែរប៉ុស្តិ៍ : តើលោកអ៊ំបានដឹងពីខ្សែជីវិត របស់លោក ស៊ីន ស៊ីសាមុត យ៉ាងដូចម្ដេច ?**

-ខ្ញុំទើបបានស្គាល់លោក ស៊ីន ស៊ីសាមុត ដំបូងនៅពេល ដែលពួកខ្មែរក្រហមចាប់បញ្ជូន ទៅដាក់គុកជាមួយគ្នានៅក្នុងមណ្ឌលប្រល័យ ពូជសាសន៍មួយឈ្មោះកោះកណ្ដុរ ក្នុងឆ្នាំ 1977 កាលណោះ លោក ស៊ីន ស៊ីសាមុត គាត់បានស្នាក់ នៅបណ្ដោះអាសន្ននៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្ដាល រយៈពេល៦ខែរួចហើយ ។

**ខ្មែរប៉ុស្តិ៍ : តើលោកស្គាល់សិល្បករណាខ្លះ ដែលជាប់គុកនៅទីនោះ ?**

-កាលពីឆ្នាំ 1977 ពួកខ្មែរក្រហមគេបាន ចាប់ខ្ញុំដាក់គុក ព្រោះគេចោទប្រកាន់ថា ខ្ញុំជា មនុស្សអ្នកមាន ហើយបម្រើសក្ដិភូមិចក្រពត្តិ ហើយខ្ញុំស្គាល់ពួកគាត់តាមរយៈការចុះទៅធ្វើ ការងារ និងនៅពេលសួរចម្លើយពេលនោះខ្ញុំភ្ញាក់ ខ្លួនព្រឺត ព្រោះគាត់ឮថាឈ្មោះ ស៊ីន ស៊ីសាមុត ហើយគេបានឱ្យពួកគាត់មកធ្វើការជាក្នុងក្រុម ជាមួយគ្នាមានលោក ឡាញ់ ដួរ៉ូ តារាភាពយន្ត ខ្មែរ, ខ្ញុំបានស្គាល់ច្បាស់ណាស់ពេលនោះពួកគាត់ ធ្វើជាងឈើ ធ្វើគ្រែធ្វើរនាប ហើយពេលសំរាក រួមគ្នាក្នុងបន្ទប់តែមួយប៉ុណ្ណោះ និងសំណេះ សំណាលជាមួយគ្នាអំពីរឿងរ៉ាវជីវិតដូចជាមួយ ថ្ងៃៗគាត់គ្រហឹមច្រៀង ដែលធ្វើឱ្យពួកឃាតក ប៉ុល ពត ចាប់អារម្មណ៍ ។

**ខ្មែរប៉ុស្តិ៍ : តើលោក ធ្លាប់ស្គាល់មជ្ឈមណ្ឌល ប្រល័យពូជសាសន៍ផ្សេងៗ ទៀតដែរឬទេ ?**

ចាប់តាំងពីឆ្នាំ 1977 ដល់ឆ្នាំ 1978 ខ្ញុំបានឃើញ យ៉ាងជាក់ស្ដែងចំពោះលោក ស៊ីន ស៊ីសាមុត ត្រូវពួកខ្មែរក្រហមប្រើគាត់មារាងកាយទ្រុឌ ទ្រោមស្បែកដណ្ដប់ឆ្អឹង ទាំងខ្ញុំខិតខំទាំងស្មារតី និងកម្លាំងចិត្ត ព្រោះខ្លាចអង្គការថ្នាក់លើយក ទៅកំទេច ។ ខ្ញុំមានស្គាល់មណ្ឌលប្រល័យពូជ-សាសន៍មួយចំនួនដូចជាគុកកោះកណ្ដុរ ពោធិបាន-លើ និងគុក3ទៀតដែលយើងមិនសូវចាំច្បាស់ ។

**ខ្មែរប៉ុស្តិ៍ : តើការរស់នៅក្នុងគុកជាមួយ លោក ស៊ីន ស៊ីសាមុត រស់នៅយ៉ាងដូចម្ដេចដែរ?**

-ការរស់នៅក្នុងគុក លោក ស៊ីន ស៊ីសាមុត ជា មនុស្សសាមញ្ញម្នាក់ ហើយគាត់មានអនាម័យ និងរម្លឹកពីសុខភាពការហូបចុកតែគាត់ស្គមស្គាំង ស្លេកស្លាំងនិយាយខ្សិបៗថា អ្វីៗទាំងអស់ដែល លោកបានច្រៀងបន្សល់មរតកសំរាប់មិត្តស្នេហា បទចម្រៀងនោះ គួរតែពិចារណាទៅ ពីព្រោះ ជីវិតមនុស្សម្នាក់ៗសុទ្ធសតែជួបប្រទះរឿងព្រាត់ ស្លាប់ព្រាត់រស់ទាំងក្ដីវេទនាដូចរូបលោកជាដើម ។

**ខ្មែរប៉ុស្តិ៍ : តើលោក ស៊ីន ស៊ីសាមុត ស្លាប់ នោះដោយសារអ្វី ?**

-អង្គការថ្នាក់លើបានរៀបចំអ្នកទោសប្រជុំ ទាំងអស់ឱ្យសារភាពត្រង់ៗ ចំពោះមុខអង្គការ ពេលមួយនោះលោក ស៊ីន ស៊ីសាមុត បានសារ ភាពមុនគេថា គាត់សូមឱ្យស្នើដល់សមមិត្តបង




យកគាត់ទៅភ្នំពេញឱ្យគាត់ច្រៀងចម្រៀងបដិ-វត្តន៍ ហើយតែងនិពន្ធដោយ ខ្លួនឯងជូនអង្គការ បដិវត្តន៍បាន ។ ពេលនោះពួក ទាហាន ប៉ុល ពត ក៏យក លោក ស៊ីន ស៊ីសាមុត ដាក់គុកដោយឡែក គឺ 1- ស៊ីន ស៊ីសាមុត និង 2- លោក ឡាញ់ ដួរ៉ូ តារាភាពយន្តខ្មែររស់នៅក្នុងបន្ទប់ផ្សេងៗគ្នា ។

-ចាប់តាំងពីឆ្នាំ 1978-1979 ខ្មែរក្រហមចាប់ ផ្ដើមរឹតបន្តឹងខ្លាំងគ្រប់មជ្ឈមណ្ឌលប្រល័យពូជ សាសន៍ និងបណ្ដេញអ្នកពាក់ព័ន្ធ (C.I.A) យួន នៅមជ្ឈមណ្ឌលទាំងខ្សែៗយកទៅសម្លាប់យ៉ាង ព្រៃផ្សៃ ។ ចំណែកគាត់ត្រូវគេបំបែកចេញពី បន្ទប់ជិតលោក ស៊ីន ស៊ីសាមុត ហើយគេឱ្យដាំ បាយឱ្យអ្នកទោស និងជាអ្នករកត្រីពេលនោះ ស្នូរគ្រាប់កាំភ្លើងដៃ និងគ្រាប់ផ្លោងលាន់គ្រប់ទិស ពួកខ្មែរក្រហមនៅតែបន្តសម្លាប់អ្នកទោសទាំង ស្រីប្រុសមួយយប់ៗ រាប់រយនាក់ ។

ពេលយប់មួយខ្ញុំបានលបមើលឃើញគេចាប់ លោក ស៊ីន ស៊ីសាមុត និងលោក ឡាញ់ ដួរ៉ូ មក សួរចម្លើយនៅលើគ្រែមួយជាប់បន្ទប់ ។ ពួកខ្មែរ ក្រហមនិយាយថាត្រូវស្មោះត្រង់ជូនអង្គការថា ពេលនោះអ្នកទោសឆ្លើយថាខ្ញុំឈ្មោះ ស៊ីន ស៊ី-សាមុត ចំណែកមិត្តភក្ដិខ្ញុំមួយនេះជាតារាភាព យន្តខ្មែរឈ្មោះមិត្ត ឡាញ់ ដួរ៉ូ មួយសន្ទុះក្រោយ មកមេឃងងឹតប្រហែលម៉ោង11យប់ខ្ញុំលបមើល តាមប្រហោងក្ដារបន្ទប់ដេកព្រិលៗឃើញមាន ក្មេងៗចំនួន4 ឬ5នាក់ មានស្ពាយកាំភ្លើង អូសជី បានហៅថា មិត្តបងពីរនាក់នេះចេញមកអង្គការ ត្រូវការបញ្ជូនមិត្តបងទៅភ្នំពេញវិញ នៅពេល យប់ ព្រោះអង្គការលាក់ការខ្ពស់ ។

ពេលយប់កាន់តែជ្រៅខ្ញុំលបមើលទៀត ខ្ញុំ បានឃើញគេចងដៃលោក ស៊ីន ស៊ីសាមុត និង ក្រណាត់ស្បង់លោក រួចបណ្ដើរចេញទៅទិសខាង លិចត្រង់ចំណុចរណ្ដៅកប់សពរួមក្នុងទឹកដីភូមិ ពោធិបានលើ ស្រុកកោះធំ ខេត្តកណ្ដាល ដែល ជាមជ្ឈមណ្ឌលប្រល័យពូជសាសន៍នោះមាន ឈ្មោះថា មណ្ឌលប្រល័យពូជសាសន៍កោះកណ្ដុរ ។

សារព័ត៌មានខ្មែរប៉ុស្តិ៍នឹងធ្វើការស្រាវជ្រាវ នៅប្រភពព័ត៌មានបន្តរអំពីជីវិតលោក ស៊ីន ស៊ីសាមុត និងអ្នកស្រី រស់ សេរីទ្ធា និងកន្លែង ស្លាប់ពិតនៅលេខក្រោយទៀត ៕



នាទី ប្រវត្តិសាស្ត្រ

# ទំព័រហ្វីឡាដែលហ្វីយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយ : ពិនសំខុន** ***តពីលេខមុន***

**២៤ មេសា** : ខៀវ សំផន និង ហ៊ូ យន់ បានលបគេចខ្លួនចូលព្រៃយ៉ាងសម្ងាត់, សមាជិកសភានិន្នាការស្តាំនិយម បានប៉ុនប៉ុងដកអភ័យឯកសិទ្ធ ហ៊ូ នឹម តែមិនបានសម្រេច ។

**៣០ មេសា** : លន់ នល់ បានលាលែងពីតំណែងជានាយករដ្ឋមន្ត្រី ។

**១ ឧសភា** : រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី២៣ ដឹកនាំដោយលោក សឺន សាន សិស្ស និងនិស្សិត១ម៉ឺនប្រាំពាន់នាក់ ធ្វើបាតុកម្មនៅភ្នំពេញ ប្រឆាំងនឹងការសង្ស័យថា មានគេសម្លាប់លោក ខៀវ សំផន និង ហ៊ូ យន់ បាតុកម្មនេះបានធ្វើឡើងអស់រយៈពេលជាច្រើនថ្ងៃ ។

**៩ ឧសភា** : កម្ពុជាទាមទារឱ្យសហគមន៍អន្តរជាតិ ទទួលស្គាល់ព្រំប្រទល់ដែនកម្ពុជាកំណត់ដោយបារាំង ឆ្នាំ១៩៥៤ ។

**៣១ ឧសភា** : យូនយៀកកុង បានទទួលស្គាល់ព្រំដែនខ្មែរ ឆ្នាំ១៩៥៤.

**ខែមិថុនា** : ជា ស៊ីម និង ហេង សំរិន បានរត់ចូលព្រៃ ។

**៨ មិថុនា** : ប្រទេសវៀតណាមខាងជើងទទួលស្គាល់ព្រំដែនខ្មែរ ឆ្នាំ ១៩៥៤ ។

**២៤ មិថុនា** : និស្សិតខ្មែរបានចូលទៅវាយកំទេចទីស្នាការកាសែត " ខ្មែរឯករាជ្យ " ដែលដឹកនាំដោយ ស៊ឹម វ៉ា ។

**១៣ កក្កដា** : សម្រេចធ្វើខេមរយានកម្មម្តងបន្តិចៗ ក្នុងកម្មវិធីសិក្សា ករិតមធ្យម និងករិតឧត្តមសិក្សា ។

**២ កញ្ញា** : សីហនុ បិតសមាគមមិត្តភាពខ្មែរ-ចិន ដែលដឹកនាំដោយ ហ៊ូ នឹម និង ភោគ ឆាយ សមាគមនេះបានចែកចាយ " សៀវភៅក្រហម " របស់ ម៉ៅ សេទុង ។

**១១ កញ្ញា** : បិតសារព័ត៌មានទាំងអស់នៅសល់តែ៤ ដែលក្រសួង ព័ត៌មានត្រួតពិនិត្យ. សេរីភាពនៃសារព័ត៌មានត្រូវបានលប់បំបាត់. អ្នកជាវកាសែតបារាំង " ឡឺម៉ុងដឺ " បានត្រូវប៉ូលិសតាមដាន, សមាគមនិស្សិតដឹកនាំ ដោយ ភោគ ឆាយ ត្រូវបានបិទទ្វារ ។

៣០ កញ្ញា : សីហនុ បានថ្លែងការណ៍ក្នុងតំបន់ដែល ហ៊ូ នឹម ជាប់ឆ្នោត នៅចំពោះមុខ ហ៊ូ នឹម ថា " ហ៊ូ នឹម មានមុខយួន ឬចិន " ហើយត្រូវ "បណ្តេញចេញពីសហគមន៍ជាតិ " ។

៥ តុលា : សីហនុ បានវាយតម្លៃថា ហ៊ូ នឹម ជាជនក្បត់ អាចត្រូវកាត់ ទោសដោយតុលាការសិក ។

៧ តុលា : ហ៊ូ នឹម បានភៀសខ្លួនទៅភ្នំក្រវ៉ាញ . មានការចាប់ខ្លួនគ្រូបង្រៀន និងសិស្សជាច្រើន ហើយច្រើនទៀតត្រូវបានសម្លាប់ចោល ។

២៥ តុលា : សីហនុ ចោទប្រកាន់ " ខ្មែរខៀវ " និង " ខ្មែរក្រហម " កូនសិស្ស និងគ្រូបង្រៀនរាប់ពាន់នាក់រត់ចូលព្រៃ ។

២៧-២៩ ធ្នូ : សមាជជាតិរបស់សង្គម-រាស្ត្រនិយមលើកទី២៤

**(នៅមានត)**

# ពុទ្ធប្បវត្តិអមដោយរូបភាព
## A Pictorrial Biography of Saky amuni Buddha

**ដោយ : អ៊ឹម លឿម**
**(តពីលេខមុន)**



❖រូបភាព និងរឿងដើមជាភាសាថៃដោយ គុណាប៉ាយុតា
❖បកប្រែជាភាសាចិន ដោយ ភិក្ខុ ជែន ហាយ
❖បកប្រែជាភាសាអង់គ្លេស ដោយ ហ្សិត .អេ.លី
❖ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី
❖បកប្រែជាភាសាខ្មែរ ដោយភិក្ខុ គង់ អាំ

២២-ថ្ងៃមួយព្រះសុទ្ធត្ថកុមារទ្រង់កំពុងរត់លេងជាមួយមិត្តភ័ក្រ្តជាច្រើនក្នុងសួនឧទ្យាននៃព្រះរាជវាំង ក្នុងនោះ ក៏មាន ព្រះរាជកុមារ **ទេវទត្ត** ដែរ ដែលត្រូវជាបងប្អូនជីដូនមួយរបស់ព្រះអង្គ ។ ព្រះរាជកុមារ **ទេវទត្ត** មានចរិកខុសគ្នាស្រឡះពីព្រះសុទ្ធត្ថរាជកុមារ ។



២៣-ព្រះសុទ្ធត្ថកុមារទ្រង់ជាកុមារស្លូតបូតសុភាពរាបសារណាស់ ព្រះទ័យព្រះអង្គពោរពេញទៅដោយមេត្តា និងការសន្តោសប្រោសប្រណីចំពោះមនុស្សសត្វទាំងឡាយ ។ ព្រះអង្គទ្រង់មិនដែលធ្វើអាក្រក់ចំពោះសត្វណាដល់ម្តងឡើយ ព្រះអង្គទ្រង់តែងតែជួយដល់សត្វដែលត្រូវគេធ្វើបាប ។ ចំណែកឯ **ទេវទត្ត** ជាមនុស្ស កាចឃោឃៅ ជាអ្នកគិតតែបៀតបៀន និន្នាឈ្នានីសគេ និងចូលចិត្តតែខាងកាប់សំលាប់ ។ ដូចក្នុងថ្ងៃនេះ ទេវទត្ត កំពុងកាន់ធ្នូ និងស្ពាយគ្រាប់ព្រួញយ៉ាងច្រើន ហើយក៏បាញ់សំដៅទៅហ្វូងក្ងានដែលកំពុងហើរ ដើម្បីជារឿងសើចលេង ។ សត្វក្ងានមួយត្រូវព្រួញត្រង់ស្លាបក៏ធ្លាក់មកដី ។ ក្ងាននោះរងរបួសជាទម្ងន់ ហើយក៏ដល់នូវការឈឺចាប់យ៉ាងខ្លាំង ។

**(តទៅលេខក្រោយ)**

❖Original Illuatration and Naration in Thai by Gunapayuta.
❖Translation into Chinese by Bhikkhu Jan Hai.
❖Translation into English by Z.A Lu.
❖ Coloring by Yann-Fang Lee
❖Translation into Khmer by Bhikkhu Kong Am.

22- One day, Prince Siddhartha was playing with his companions in the palace garden. Many of his young companons were salso playing there. Among them was Prince Devadatta, a cousin of Prince Devadatta. whose perso-nal character was entirely diffent from the Prince's.

23- Prince Siddhartha was genial and folite, and his heart was full of mercy and benevolence. He never opppressed others, but often helped the oppressed. Prince Devadata was



cruel and jealous and fond of killing. This day Devadatta was carrying his bow and arrows, shooting the flying swans for fun. One swan was shot in the wing and fell to the ground. It was badly wounded and appeared to be in much pain. (continue Issue After)


ខ្មែរជួសជុលរថយន្ត
KHMER AUTO REPAIR
CAR INSPECTION, DIAGNOSTIC & REPAIR
ត្រួតពិនិត្យ [illegible]
• [illegible]
• [illegible] ឬ ប្រេក
• [illegible]
• [illegible]
• [illegible]
• [illegible]
• [illegible]
Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace.
5302 Rising Sun Avenue. Philadelphia, Pa 19120
215-939-5436

New World Travel II
New World Travel II
ញូវលត្រាវែលធូ
Specialized in Selling Flight Tickets
For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបាន ទិញសំបុត្រជិះនាវាសមុទ្រ- សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

# អន្តោប្រវេសន៍នៅសហរដ្ឋអាមេរិក

**ដោយ : លិនស្ទី ដឺរីង**

•••បញ្ចប់ការឆ្លើយតបទៅនឹងវាគ្មិន នៃក្លឹបសារព័ត៌មាន កាលពីលើកមុនស្តីអំពីបញ្ហាអន្តោប្រវេសន៍ នៅសហរដ្ឋអាមេរិក លិនស្ទី ដឺរីង មេធាវី បានសរសេរក្នុងលិខិតនេះថា " មានជនរស់នៅខុសច្បាប់ចំនួន ១២លាននាក់ ដែលរដ្ឋបាល ប៊ូស ក៏ដូចរដ្ឋបាល អូបាម៉ា បានយល់ស្របគ្នាថា គួរតែធ្វើច្បាប់ឱ្យអាចរស់នៅស្របច្បាប់បាន តែត្រង់បញ្ចេញច្បាប់ពេលណាបាននោះ អាចនឹងត្រូវប្រើពេលយូរ ដោយរដ្ឋបាល អូបាម៉ា ជារដ្ឋបាលដែលទទួលភារកិច្ចធ្ងន់ធ្ងរ និងច្រើនមុខ មិនដែលមានតាំងពី ៥០ឆ្នាំមុនមក " ...

## Immigration Update

**By Lindsay Doering**

Now that the new administration is up and running, it is a good time to check in on one of the most pressing issues facing the United States: immigration. The immigration issue is basically comprised of two parts: legislation (creating new laws, or changing the current laws) and enforcement.

On the legislative front there has been recent talk about reform that would address existing populations as well as new immigration. The complexity of this issue will mean that it will take a long time to build a consensus, even within the majority Democrat party, let alone the Republicans. The most important area for reform is to determine the status of the approximately 12 million illegal aliens currently living in the US. President Bush proposed a plan that would give illegal aliens a pathway to citizenship. President Obama has essentially agreed with this proposal. However, the current economy will likely dampen public support for this proposition, which was never strong to begin with.

While visiting Costa Rica in late March, US Vice President Joe Biden confirmed that the legalization of undocumented aliens was unlikely this year due to the economic crisis and rising unemployment.

"It's hard to tell voters, when unemployment is increasing, when they are losing their jobs and homes, that what we should do is legalize foreigners and stop deportations," said the Vice President.



Mexico normally plays a major part in any immigration debate in the United States. The recent Mexican drug wars along the U.S. border have perhaps been another reason for reluctance to move forward with any reform measures.

With regard to enforcement, we can look at several appointments made by Obama. Secretary Napolitano has been named head of the Department of Homeland Security. She has a wealth of immigration experience. She has indicated that her primary focus on enforcement will be on employers who hire illegal immigrants rather than on the illegal immigrant community itself. However, Obama appointed Thomas Perez over Thomas Saenz to head the Civil Rights Division of the Justice Department. Saenz is more closely tied to immigrant rights and has a stronger liberal tracked record than Perez. So, it remains to be seen how enforcement will play out.

The President will be unable to avoid the immigration issue. However, this administration is dealing with more problems, both domestically and abroad, than any administration in over 50 years. It is almost impossible to predict what, if anything, will happen on this issue given the current situation; however, it seems unlikely that comprehensive legislation will be passed in the first years of this administration.


**ការិយាល័យមេធាវី លិនហ្សេ ដឺរីង**

**LAW OFFICE OF LINDSAY DOERING**

ទទួលការពារផលប្រយោជន៍លោកអ្នកករណីទូទៅតាមផ្លូវច្បាប់ដូចជា :

- ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
- ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសម្បែង ដីធ្លីជាដើម ។
- ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ករណីអន្តោប្រវេសន៍
- ឬករណីឧក្រិដ្ឋកម្ម ។ល។



ធ្លាប់មានបទពិសោធន៍ខ្ពស់ ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។

General practice law office handling matters in :

Corporations and business Transations
Read Estate
Car Accidents
Work Place Injury
Immigration
Criminal Defense
Experienced, professional service and reasonable rate. Interpreter available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com



**ANGKOR AUTO SERVICE, INC.**

**ហាងជួសជុលរថយន្ត "អង្គរ"**

4835 N. 16th Street. Tel : (215) 455-7810
Philadelphia, Pa 19141 Ricky : (215) 485-1425

Specializing in Body Kit and Custom Paint

ជំនាញខាងជួសជុលតួរថយន្ត និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រ វាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អ៊ិនស្វ៊ូរិន បានផង យើងផ្តល់សេវាគ្រប់យ៉ាង :

-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C









បើកពីម៉ោង ៩ ព្រឹក ដល់ម៉ោង៥ល្ងាច ពីថ្ងៃច័ន្ទ ដល់ ថ្ងៃ សៅរ៍

ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

តមកពីទំព័រទី ១០ 

## មានអ្វីប្លែកនៅឆ្នេរខាង...

-អង្គប្រជុំដែលបានបើកឡើងដោយលោក ប៉ាត ស៊ុយគ្រី រដ្ឋមីទីនីសូតា រួចមកដឹកនាំអង្គប្រជុំដោយវេជ្ជបណ្ឌិត កែវ សម្បត្តិ ម៉ាសាឈូសែត បានបោះឆ្នោតជ្រើសរើសតាំងគណកម្មាធិការថ្មីប្រចាំសហរដ្ឋ-អាមេរិក និងកាណាដា លទ្ធផលគឺ លោក ញ៉ាយ ចំរើន រដ្ឋផែនស៊ីវែនៀ ជាប្រធាន លោក ទូន យក់ដា ជាអនុប្រធាននៅកាណាដា លោក គឹម ចាន់វង្ស អគ្គ-លេខាធិការ នៅរដ្ឋវ៉ាស៊ីនតោន និងលោក កែវ សម្បត្តិ ជាអគ្គហិរញ្ញិក ។ ព័ត៌មានដែលខ្មែរប៉ុស្តិ៍ ទើបបានទទួលចុងក្រោយនេះ គឺលោក សម រង្ស៊ី និង លោក កឹម សុខា ប្រធានគណបក្សប្រឆាំងទាំង ពីរនៅកម្ពុជា នឹងចេញដំណើរដំណាលគ្នាមកកាន់សហរដ្ឋអាមេរិក នេះ នៅពាក់កណ្តាលខែឧសភា។ គឺបន្ទាប់ទៅបំពេញការងារនយោបាយរួមគ្នានៅរដ្ឋធានី វ៉ាស៊ីនតុន រួចមកអ្នកតាំងពីនឹងមកហ្វីឡាដែលហ្វីយ៉ានាំយកព័ត៌មានជាក់ស្តែងមកជូនពលរដ្ឋខ្មែរមុននឹងបន្តដំណើរទៅជួបខ្មែរឯទៀតៗនៅតំបន់ផ្សេងៗ។

សហគមន៍ខ្មែរនៅក្រៅប្រទេស ជាពិសេសនៅសហរដ្ឋអាមេរិក ត្រូវបានគេទទួលស្គាល់ថា ជាកម្លាំងគាំទ្រដល់ចលនាប្រជាធិបតេយ្យនៅកម្ពុជាដ៏សំខាន់បំផុត ជាពិសេសចលនាគាំទ្រដល់បក្សប្រឆាំងបច្ចុប្បន្ន ។ គណបក្សប្រឆាំង គឺសំដៅទៅលើគណបក្ស សម រង្ស៊ី ដែលមានសមាជិកនៅក្នុងសភាជាតិចំនួន២៦រូប និងគណបក្សសិទ្ធិមនុស្សមានសមាជិកនៅក្នុងសភាជាតិចំនួន៣រូប ។ រីឯគណ-បក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សនរោត្តមរណឫទ្ធិ ដែលមានសមាជិកសភាមួយក្រុមមានពីររូបនោះ ពុំត្រូវបានចាត់ទុកថា ជាគណបក្សប្រឆាំងទេ ហើយក៏ពុំមានការគាំទ្រពីសហគមន៍ខ្មែរក្រៅប្រទេសនោះទេ ។ គណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជាមានមូលដ្ឋានគាំទ្រក្រៅប្រទេសនៅហ្វីឡាដែលហ្វីយ៉ាតែពុំឃើញមានសកម្មភាពនយោបាយឃោសនាពន្យល់ពលរដ្ឋអ្វីទេ ៕


















តមកពីទំព័រទី០១ **លោក ហោ ណាំហុង**

រថយន្តសង្គ្រោះបន្ទាន់បានយកលោក ហោ ណាំហុង ទៅកាន់មន្ទីរពេទ្យ ជាមួយនឹងឯកអគ្គរាជទូតខ្មែរ ពីររូប លោក ជា កុសល និង លោក ហែម ហ៊ាង ទៅជាមួយផង ។ គេពុំដឹងប្រាកដអំពីអគាររោគរបស់លោកឧបនាយករដ្ឋមន្ត្រីទេ តែមតិមួយចំនួននិយាយខុសៗគ្នាថា មកពីជំងឺបេះដូង ខ្លះថាលោកមានការនឿយហត់ដោយសារការធ្វើដំណើរផ្លូវឆ្ងាយ ។ ដំណឹងដែលយើងទទួលបាន ត្រូវបានមន្ត្រីខ្មែរ ដែលបានចូលរួមក្នុងពិធី ខិតខំលាក់ខ្ទប់មិនចង់ឱ្យខ្ចរខ្ចាយ ដោយគេយល់ថា វាជាដំណឹងមិនល្អ ។

អគ្គកុងស៊ុលខ្មែរថ្មីនេះ នឹងត្រូវដឹកនាំដោយលោកអគ្គកុងស៊ុលថ្មីថ្មោង លោក អ៊ូ សុវណ្ណ ដែលធ្លាប់ជាសមាជិកសំខាន់របស់គណបក្សជាតិខ្មែរ របស់ សម រង្ស៊ី ហើយទើបនឹងចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា កាលពីពីរឆ្នាំមុននេះ ។

អគ្គកុងស៊ុលខ្មែរ នៅឡូវែល នឹងមានតួនាទីដំបូង គឺជួយសម្រួលដល់អ្នកធ្វើដំណើរចេញចូលកម្ពុជា ឱ្យអាចធ្វើលិខិតឆ្លងដែនការបានឆាប់រហ័ស និងជួយសម្រួល ផ្នែករដ្ឋបាលដល់សិស្ស ឬនិស្សិតខ្មែរ ដែលបំពេញការ សិក្សានៅសហរដ្ឋអាមេរិក ។

អាស័យដ្ឋានអគ្គកុងស៊ុលខ្មែរ ប្រចាំក្រុងឡូវែល រដ្ឋម៉ាសាឈូសែត : 111 CHELMFORD Street
Lowell , MA 01851
ទូរស័ព្ទ : (978)- 735 4539.

តមកពីទំព័រទី០៣ **សិទ្ធា សាន ក្លាយខ្លួន...**

បន្តការជួយទៅអ្នកដទៃឱ្យជោគជ័យក្នុងការងារដ៏ហ្មត់ចត់ដែលវាគឺជាម្ចាស់នៃប្រយោជន៍របស់អ្នក ។ ដូច្នេះក្នុងនាមយើងជាស្ត្រីក៏មានចំណែកក្នុងជំនាញកសាងទំនាក់ទំនងសហការ និងកសាងមតិរួម ដើម្បីអភិវឌ្ឍន៍សង្គមជាតិ ។

សិទ្ធា សាន ត្រូវបានគេស្គាល់ថា ជាប្រធានក្រុងខ្មែរ ដែលស្ថាប័នមួយនេះ ត្រូវបានអាជ្ញាធរក្រុង Long Beach អនុម័តសំរេចឱ្យតំបន់សហគមន៍ខ្មែរក្លាយទៅជាក្រុងខ្មែរ Long Beach នាថ្ងៃទី 3 កក្កដា ឆ្នាំ 2007 អ្នកស្រីក៏ជាអតីតរដ្ឋមន្ត្រីជាន់ខ្ពស់ម្នាក់នៅក្នុងក្រុមហ៊ុនយន្តហោះកម្ពុជា Royal Air Cambode និងបច្ចុប្បន្នជាបុគ្គលិកធ្វើការនៅក្នុងធានាគារខ្មែរ ឈ្មោះ Golden Coast Bank ដែលខ្លួនក៏ជាក្រុមស្ថាបនិកធនាគារដែរផងនោះ ។ សិទ្ធា សាន បានលះបង់កម្លាំងកាយចិត្តឱ្យក្លាយខ្លួន ជានារីអង់អាចក្នុងសកម្មភាពជួយសហគមន៍ខ្មែរ ដែលរាល់ទង្វើទាំងអស់នេះ បានធ្វើឱ្យអង្គការលើកតម្កើង សិទ្ធិនារីឈ្មោះ Soroptimist International សម្រេចប្រគល់កិត្តិយសឱ្យជាស្ត្រីឆ្នើម (វីរៈ នារី) របស់គេនាឆ្នាំ 2009 នៅក្រុង Long Beach ដែលតម្លៃឱ្យនោះ គឺមានន័យថា "International goodwill and understanding" គួរបញ្ជាក់ថា អង្គការ Soroptimist International បានបង្កើតឡើងតាំងពីទសវត្សឆ្នាំ 1970 បម្រើកិច្ចការលើកស្ទួយផ្នែកស្ត្រីនៅគ្រប់ប្រទេសពាសពេញពិភពលោកជាង 100 ប្រទេស ៕

**United States Volunteers Joint Services Command**
**Khmer Command (អគ្គបញ្ជាការដ្ឋានខ្មែរ)**

**សេចក្តីប្រកាសនិងជំរាបជូន**

យើងខ្ញុំជាគណៈកម្មាធិការ អគ្គមេបញ្ជាការដ្ឋានខ្មែរ មានសេចក្តីប្រកាស និង ជំរាបជូនដល់បងប្អូនខ្មែររួមជាតិទាំងអស់ ដែលរស់នៅក្នុងទឹកដីសហរដ្ឋអាមេរិកទាំងមូលថា: យើងខ្ញុំបានរៀបចំពិធីលើកកិត្តិយសដល់ នាយទាហាន នាយទាហានរង ពលទាហាន ដែលនៅសេសសល់ ហើយក៏ធ្លាប់បានចូលរួមប្រយុទ្ធយ៉ាងខ្លាំង ក្នុងសមរភូមិជាមួយកងទ័ពសហរដ្ឋអាមេរិក ពេលនេះយើងទាំងអស់គ្នា ពិតជាបានទទួលនូវកិត្តិយសយ៉ាងកក់ក្តៅចេញពី ក្រសួងការពារជាតិ នៃសហរដ្ឋអាមេរិក ដែលមានឈ្មោះថា: **United States Volunteers Joint Services Command** និងធ្វើពិធីផ្តល់កិត្តិយស បំពាក់ឋានន្តរសក្តិ ដល់អ្នកដែលធ្លាប់មានគុណបំណាច់ ចំពោះប្រទេសជាតិខ្មែរ នាសម័យសាធារណៈរដ្ឋខ្មែរ ដើម្បីផ្តល់ការលើកទឹកចិត្ត និងចង់ឃើញនូវព្រឹត្តិការណ៍ថ្មីៗនេះ ដូច្នេះសូមអញ្ជើញចូលរួមឱ្យបានកុះករ ហើយក៏ជាប្រវត្តិសាស្ត្រមួយ ដល់បងប្អូនខ្មែរជំនាន់ក្រោយ ។ "ដើម្បីនាំទឹកចូលស្រែ ត្រូវតែជីកប្រឡាយ" នេះជាពាក្យស្លោកមួយតែប៉ុណ្ណោះ ។

**កាលបរិច្ឆេទ:** ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៩ យប់ថ្ងៃ សៅរ៍ (On Saturday night, May02, 2009)

**ទីកន្លែង :** New Golden Palace
**801-21 Washington Ave**
**Philadelphia, PA 19147**
**Tel: 215-214-9239, 267-234-5303**

**ពេលវេលាចាប់ផ្តើម** ម៉ោង: **2PM – 4PM** ភារៈកិច្ចអស់នាយទាហាន នាយទាហានរង ពលទាហាន ទាំងអស់នៅទីកន្លែងខាងលើ ។
ម៉ោង: **4PM -10PM** ធប់កម្មវិធី ។

ដូច្នេះហើយសូមអញ្ជើញបងប្អូនខ្មែររួមជាតិទាំងអស់ មកចូលរួម ហើយជួយឧបត្ថម្ភដល់ការដ្ឋានខ្មែរយើងនេះឱ្យបានជោគជ័យ ដើម្បីធ្វើកិច្ចការទៅមុខទៀត ហើយនេះក៏ជាជំហានទីមួយដែរ ដែលខ្មែរយើងទើបតែជួបប្រទះ ។ បើលោកអ្នកចង់ឃើញព្រឹត្តិការណ៍នេះ សូមអញ្ជើញរួសរាន់មកចូលរួមតាមកាលបរិច្ឆេទខាងលើនេះ ។ ព័ត៌មានបន្ថែម សូមមេត្តាទាក់ទងទៅទូរស័ព្ទ :

- លោក **សំរិទ្ធិ ថែម** ប្រចាំរដ្ឋ PA លេខ: 215-214-9239 ឬ 267-234-5303
- លោក **មិន ម៉ុនរាយ** ប្រចាំរដ្ឋ WA លេខ: 253- 227-2062 ឬ 253- 861-4205
- លោក **ម៉ែន តែម** ប្រចាំរដ្ឋ MA លេខ: 978-551-7444
- អ្នកស្រី **ម៉ុំ** ប្រចាំរដ្ឋ CA លេខ: 562-489-4526

**សូមអរគុណ !**


THE WEDGE MEDICAL CENTER

# ដំណឹងរកអ្នកធ្វើការ

**"វេជ មេឌីខលសេនធ័រ"** រកអ្នកធ្វើការច្រើននាក់ចេះនិយាយភាសាខ្មែរមានកំរិតសិក្សាថ្នាក់ **"អនុបណ្ឌិតខាងព្យាបាលសុខភាពផ្លូវចិត្ត"** ។ ធ្វើការយកកំរៃតាមពេលមកធ្វើការក៏បាន ឬពេញម៉ោងក៏បាន ។ ធ្វើការនៅតំបន់ ឡូហ្គាន់ នឹងនៅហ្វីឡាដែលហ្វៀ ខាងត្បូងជាមួយនឹងអ្នកជំងឺ ដែលត្រូវការព្យាបាលខាងជំងឺផ្លូវចិត្ត ។

**សូមផ្ញើប្រវត្តិរូប តាមលិខិតធម្មតាទៅ :**

LORI WATSON @1939 SOUTH JUNIPER STREET
PHILADELPHIA, PA 19148

The Wedge Medical Center is seeking the Cambodian-speaking Master's Level Mental Health Therapists for the Logan and South Philadelphia Sites to provide Outpatient Mental Health Therapy (Fee-For-Service or Full Time). All Interested Candidates should 'regular mail' their resumes to LORI WATSON @ 1939 South Juniper Street, Philadelphia, PA 19148.